


Websites: WatKhemaraRatanaram.org or WatKhmers.org

# មហាវេស្សន្តរជាតក

សម្រាប់ទេសន៍

ទី ២

# កណ្ឌហេមពាន្ត

ប្រដាប់ដោយគាថា ១៣៤
បោះពុម្ពលើកទី ២
ចំនួន ៥.២០០ ច្បាប់

**ភ្នំពេញ**
ការផ្សាយរបស់អាគារបោះពុម្ពផ្សាយវប្បធម៌
១៩៩០

Websites: WatKhemaraRatanaram.org or WatKhmers.org

# មហាវេស្សន្តរជាតក

## ទី ២

## **ករណ្ឌហេមពាន្ត**

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ឥតិ សា វរេ គហេត្វា តតោ ចុតា មទ្ទរញ្ញោ អគ្គមហេសិយា កុច្ឆិម្ហិ និព្វត្តិ ។

ព្ធដ៏កាលនោះ រីឯព្រះនាងសុបារសុប្បតី ដ៏ជាស្រីល្អអស់អង្គ ទ្រង់នូវរូបមានលក្ខណៈប្រសើរនោះ ព្រះនាងទទួលយកព្រះពរទាំង ១០ ប្រការ អំពីព្រះឥន្ទ្រាធិរាជហើយ ក៏ច្យុតស្រុតចុះមកចាប់បដិសន្ធិ ព្ធដ៏ផ្ទៃអគ្គមហេសី នៃព្រះបាទមទ្ទរាជព្ធដ៏មាតុលនគរ ។

តាយ ជាយមានាយ ចន្ទនចុណ្ណេន បរិប្ផោសិតេន វិយ សរីរេន ជាតត្តា ។ រីព្រះនាងសុបារសុប្បតីសោត កាលណា ព្រះនាងប្រសូតចេញមកអំពីផ្ទៃ នៃព្រះអគ្គមហេសីព្រះបាទមទ្ទរាជ នោះហើយ ដ៏មានសម្បុរសនោះល្អ បីដូចអ្នកយកនូវលំអិតខ្លឹមច័ន្ទន៍

Websites: WatKhemaraRatanaram.org or WatKhmers.org

មកលាបស្រឡាបអស់អង្គ ហេតុតែព្រះនាងមានកំណើតដូច្នោះ ទើបលោកមកសន្មតកត់សំគាល់ នូវព្រះនាមនាងថា «ព្រះនាងសុបារសុប្បតីកុមារី» លុះព្រះនាងចំរើនធំឡើង ព្រមនូវអស់បរិពារផងទាំងឡាយច្រើន មានព្រះរូបឆោមនោះល្អ បីដូចស្រីទេពអប្សរបវរកញ្ញានៅនាសួគ៌នាយហោង ។

អថ ធំ សិរិមហារាជា អត្តនោ បុត្តស្ស សញ្ជយ-កុមារស្ស អត្ថាយ អានេត្វា ។ បពិត្រអើយ រីព្រះនាងសុបារ-សុប្បតីកុមារី លុះព្រះនាងមានព្រះជន្មបាន ១៦ ព្រះវស្សាបរិបូណ៌ហើយក្តូវ ព្រះបាទសិរិមហារាជ ឲ្យទៅអញ្ជើញព្រះនាងមកអភិសេកមួយអន្លើនឹងថៅសញ្ជ័យកុមារ ឲ្យឡើងសោយរាជ្យសម្បត្តិ ទុកព្រះនាងជាអគ្គមហេសីធំក្រៃលែងអស់ស្រីព្រះស្នំផងទាំងឡាយ ១៦ ពាន់តេន វុត្តំ ហេតុនោះហោង ព្រះអង្គមានព្រះបន្ទូលនឹងព្រះសារីបុត្តត្ថេរស្វូត្រនូវបាទព្រះគាថាដូច្នេះថា ៖

តតោ ចុតា សា ផុស្សតី ខត្តិយេ ឧបបជ្ជថ
ជេតុត្តរម្ហិ នគរេ សញ្ជយេន សមាគមីតិ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ភោ សារីបុត្ត ហៃធម្មសេនាបតីស្រីសារីបុត្តអើយ រីព្រះនាងសុបារសុប្បតីទេវី ព្រះនាងច្យុតស្រុតចាកទេវលោក ក៏បានមកកើតក្នុងត្រកូលក្សត្រខត្តិយវង្ស ហើយបានជាអង្គអគ្គមហេសី នៃព្រះបាទស្រីសញ្ជ័យជាក្សត្រថ្លៃប្រសើរ សោយរាជ្យសម្បត្តិឋិតនៅនាជេតុត្តរនគរ ។ អថ ជំ សត្ថោ គ្រានោះ សម្ដេចសក្កទេវរាជ ឋិតនៅនាសួគ៌ត្រៃត្រិង្សទេវលោក ស្ដេចបើកទិព្វចក្ខុរមិលមើលចុះមកយល់ព្រះនាងសំរិទ្ធិនូវព្រះពរ ៩ ប្រការបរិបូណ៌ ដូចព្រះនាងប្រាថ្នានោះកូវ ព្រះឥន្ទ្រក៏ទ្រង់រំពឹងដូច្នេះថា ឱពរ ១០ ប្រការដែលអញប្រសិទ្ធិឲ្យព្រះនាងសុបារសុប្បតីទេវីនោះមិញ នាពរទាំង ៩ ប្រការនោះ ព្រះនាងបានបរិបូណ៌ហើយ នៅសល់ខានតែពរមួយ ព្រះនាងប្រាថ្នាឲ្យបានព្រះរាជបុត្រប្រុសនោះមិញ ពុំទាន់បានបរិបូណ៌នៅឡើយ ថាបើដូច្នោះកូវ អញនឹងបំពេញឲ្យបានដូចសេចក្ដីប្រាថ្នានោះហោង ។

កាលនោះ ព្រះបរមពោធិសត្វមហាបុរសរ័ត្ន ស្ដេចឋិតនៅនាពិភពត្រៃត្រឹង្សនាយ ។ សម្ដេចព្រះឥន្ទ្រាធិរាជ ស្ដេចទ្រង់ជ្រាប

Websites: WatKhemaraRatanaram.org or WatKhmers.org

សភាពព្រះជន្មព្រះពោធិសត្វថា នឹងសំរិទ្ធិបរិបូណ៌ហើយ ព្រះឥន្ទ្រាធិរាជក៏ចូលទៅកាន់ព្រះពោធិសត្វ ហើយនិមន្តដោយបទបាលីថា **មារិស តយា មនុស្សលោកំ គន្តុំ វដ្តតិ ។ មារិស** បពិត្រព្រះអង្គដ៏មានបុណ្យបារមីច្រើនអើយ សូមអារាធនានិមន្តព្រះអង្គ ស្តេចលីលាចុះទៅទូន្មានសត្វផងទាំងឡាយ នៅនាមនុស្សលោកនាយ ថាបើព្រះអង្គលីលាចុះទៅហើយ ព្រះបារមីព្រះអង្គនឹងសំរិទ្ធិបរិបូណ៌ ប្រាកដហោង ។

កាលនោះ ព្រះបរមពោធិសត្វ ស្តេចទទួលនិមន្តន៍សម្តេចព្រះឥន្ទ្រាធិរាជហើយ ទើបព្រះអង្គច្យុតស្រុតចុះមកអំពីស្ួគ៌ទេវលោកនាយមកចាប់បដិសន្ធិ ឰដ៏ក្នុងព្រះមាតុទរបវរ នៃព្រះនាងសុបារ-សុប្បតី ដ៏ជាព្រះអគ្គមហេសីថ្លៃ ព្រះបាទស្រីសញ្ជ័យដែលទ្រង់សោយរាជ្យសម្បត្តិ ឋិតឰដ៏ជេតុត្តរនគរនោះហោង ។

**តស្ស ចេវ អញ្ញេសញ្ច ចវនជម្មានំ សដ្ឋីសហស្សានំ ទេវបុត្តានំ បដិញ្ញំ គហេត្វា ។** សម្តេចព្រះឥន្ទ្រាធិរាជប្តេជ្ញានិមន្តមិនប៉ុន្តែព្រះពោធិសត្វឯងឡើយ ហើយនិមន្តអស់ទេវបុត្រផងដទៃ

Websites: WatKhemaraRatanaram.org or WatKhmers.org

នោះច្រើនប្រមាណ ៦ ម៉ឺន ឲ្យច្យុតព្រមមួយអន្លើនឹងព្រះពោធិសត្វ នោះឯង *សក្កដ្ឋានមេវ គតោ* លុះព្រះឥន្ទ្រាធិរាជនិមន្តស្រេចហើយ ក៏ស្តេចហោះទៅកាន់ឋានលំនៅព្រះអង្គវិញហោង ។ បពិត្រអើយ រីអស់ទេវបុត្រសំណល់ក្រៃលែងនោះ សឹងច្យុតចុះមកចាប់បដិសន្ធិ ឰដ៏ផ្ទៃប្រពន្ធរាជអាមាត្យផងអស់សព្វគ្រប់ទាំង ៦ ម៉ឺននោះឯង ។ ហេតុតែព្រះបារមី នៃព្រះបរមពោធិសត្វមហាបុរវ័ត្ថវិសេស មកចាប់ បដិសន្ធិ ឰដ៏ព្រះមាតុទរបវរព្រះកន្លោង គឺព្រះនាងសុបារសុប្បតី ព្រះនាងមានព្រះរាជហឫទ័យនោះជ្រះថ្លាសទ្ធា ចង់ឲ្យទានស្មូមយាអ្នកកំសត់ទុគ៌តផងទាំងឡាយ ព្រះនាងឲ្យប្រដាប់សាលាទានទាំង ៦ សាលាទាន ៤ នោះនៅនាទ្វារព្រះនគរទាំង ៤ សាលាមួយ នោះនៅនាមុខព្រះលាន សាលាមួយទៀតនោះនៅនាក្នុងព្រះរាជវាំង ហើយព្រះនាងឲ្យចាយអស់មាសប្រាក់ កែវកង សព្វពិធវ័ត្ថផង ឱ្យ ទៅជាទានដល់អស់អ្នកស្មូម យាចកអ្នកកំសត់ ទុគ៌តផងទាំងឡាយ ក្នុង ១ ថ្ងៃៗ នោះ ៦ សែនតម្លឹងមាស ។

កាលណាបើជ្រាបដល់ ព្រះស្រីសញ្ជ័យបរមបពិត្រក្សត្រ

Websites: WatKhemaraRatanaram.org or WatKhmers.org

ប្រសើរនោះហើយ ស្តេចមានព្រះបន្ទូលឲ្យហៅអស់ព្រាហ្មណ៍ ដែលចេះទាយនិមិត្តនោះមកហើយ មានព្រះបន្ទូលដណ្តឹងថា ព្រាហ្មណ៍អើយ ចាប់ដើមតាំងអំពីព្រះនាងទេវីទ្រង់គភ៌ ព្រះនាងមានព្រះរាជហឫទ័យនោះ ជ្រះថ្លាសទ្ធាចង់តែឲ្យទាននោះ តើមានហេតុដូចម្តេច ។ ទើបព្រាហ្មណ៍ចេះទាយនិមិត្តនោះ ក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេពក្សត្រថ្លៃប្រសើរអើយ នេះហេតុអំណាចព្រះរាជបុត្រ ឋិតនៅក្នុងព្រះមាតុទរ ទើបមានព្រះរាជហឫទ័យសទ្ធាចង់តែឲ្យទាន បពិត្រព្រះមហារាជអើយ រីសម្តេចព្រះរាជបុត្រនោះ មិនគឺស្រីឡើយ គឺប្រុសឯងមិនទេឡើយ មកឋិតនៅក្នុងព្រះរាជឧទរ ថាបើចាកចេញអំពីព្រះមាតុទរ ព្រះវររាជមាតាកាលណាហើយ ព្រះអង្គមានព្រះបារមីនោះរុងរឿងថ្កើងទូទ័រទៅអស់ស្តេចទាំងសកលជម្ពូទ្វីប សឹងដ៏នាំជង្វាយភ្លាសស្លួយរ៉ៃ មកថ្វាយព្រះអង្គនោះច្រើនហោង ។

តំ សុត្វា រាជា តុដ្ឋមានសោ ហុត្វា វត្ថប្បការា ឆ ទានសាលាយោ ការាបេត្វា វត្ថប្បការំ ទានំ បដ្ឋបេសិ ។ ព្រះមហាក្សត្រាធិរាជទ្រង់ព្រះសណ្តាប់ ពាក្យព្រាហ្មណ៍ក្រាបបង្គំទូលដូច្នោះហើយ

Websites: WatKhemaraRatanaram.org or WatKhmers.org

ស្ដេចមានព្រះរាជហឫទ័យនោះ ត្រេកអរសាទរក្រៃពេក ទ្រង់ឱ្យយកព្រះរាជទ្រព្យផងទាំងពួង ព្រះរាជទានទៅព្រះនាងច្រើនក្រៃពេកជាអនេកប្រការ ។

ពោធិសត្តស្ស បដិសន្ធិគ្គហណកាលតោ បដ្ឋាយ រញ្ញោ អាយប្បមាណំ ធាម ធាហោសិ ។ រីនឹងស្រដីកាលព្រះពោធិសត្វមហាបុរសវ័ត្ថវិសេស មកចាប់បដិសន្ធិក្នុងព្រះមាតុទរបវរព្រះមាតានោះ ហេតុតែព្រះបារមីនៃព្រះពោធិសត្វនោះមិញ រីអស់ស្ដេចសកលជម្ពូទ្វីប សឹងតែនាំមាសប្រាក់កែវកង សព្វពិធវ័ត្ថមកថ្វាយសម្ដេចព្រះវររាជបិតានោះច្រើន នឹងរាប់គណនាពុំបានឡើយ ។

ទេវី មហាឆ្ដេដ បរិវារេដ គព្ភំ ធារេន្តី ។ រីព្រះនាងទេវីទ្រង់គភ៌ពោធិសត្វ មួយអន្លើនូវអស់បរិវារផងច្រើនបរិបូណ៌បាន ១០ ខែហើយ ព្រះនាងមានព្រះចំណង់នឹងចង់ទៅទតរមិលមើលព្រះនគរ ទើបព្រះនាងឲ្យទៅក្រាបបង្គំទូលព្រះមហាក្សត្រាធិរាជទ្រង់ជ្រាប ហើយមានព្រះរាជហឫទ័យនោះត្រេកអរក្រៃពេក ស្ដេចឱ្យប្រដាប់ប្រដាព្រះនគរនោះ ល្អបីដូចពិមាននៃទេវតានៅនាឋានសួគ៌

Websites: WatKhemaraRatanaram.org or WatKhmers.org

នាយ ហើយព្រះអង្គប្រើអាមាត្យ ឲ្យទៅយកសុវណ្ណសិវិកានាំមកឲ្យព្រះនាងៗ ឋិតនៅលើគ្រែសុពណ៌សិវិកានោះ ហើយក៏លីលាទៅទតរមិលមើល ហើយធ្វើប្រទក្សិណព្រះនគរ ៣ ជុំ ទើបព្រះនាងត្រឡប់មកដល់កណ្ដាលផ្លូវឈ្នួញធំកូវ ខ្យល់កម្មជ្ជវាតក៏បក់កំរើកផ្ទៃព្រះឧទរ នឹងប្រសូត្រព្រះពោធិសត្វឰដ៏កាលណោះ។ ទើបពួកអាមាត្យនាំសេចក្ដីទៅក្រាបបង្គំទូល សម្ដេចព្រះមហាក្សត្រស្ដេចទ្រង់ជ្រាបដំណឹងនោះហើយ ទើបទ្រង់ចាត់ឲ្យសង់ ព្រះដំណាក់ជាទីប្រថាប់សំរាប់ប្រសូត ព្រះនាងក៏ប្រសូត្រព្រះបរមពោធិសត្វ ឰដ៏ឋាននោះហោង ។

តេន វុត្តំ ហេតុនោះ ព្រះអង្គមានព្រះបន្ទូលនឹងព្រះមហាសារីបុត្តត្ថេរថា ៖

ទស មាសេ ធារយិត្វា  ករោន្តី បុរ បទក្ខិណំ
វេស្សាន់ វីថិយា មជ្ឈេ  ជនេសិ ផុស្សតី មមន្តិ

ហៃហាសារីបុត្តអើយ រីព្រះនាងសុបារសុប្បតីទេវី ទ្រង់គភ៌អញ្ញតថាគត បរិបូណ៌បានខែ ១០ ហើយ ព្រះនាងទៅទតមើលព្រះ

Websites: WatKhemaraRatanaram.org or WatKhmers.org

នគរប្រទក្សិណ ៣ ជុំរួចហើយ ព្រះនាងត្រឡប់វិលមកដល់កណ្ដាលផ្លូវហើយ ក៏ប្រសូតអញ្ចឹតថាគតនៅកណ្ដាលផ្លូវឈ្នួញធំ ។

មហាសត្តោ មាតុកុច្ឆិតោ និក្ខមន្តោ វិសុទ្ធោ ហុត្វា អក្ខីនិ ឧម្មិលេត្វា ។ និក្ខមិ ។ កាលណាបើព្រះមហាសត្វនោះប្រសូតចាកចេញអំពីព្រះមាតុទរបវរព្រះកន្លោង ដ៏មានព្រះអង្គនោះល្អបរិសុទ្ធ បីដូចតម្បារមាស រីព្រះនេត្រទាំងពីរនោះសោត សឹងដ៏ថ្លាស្រឡះ ហើយទតរមិលមើលទៅកាន់ព្រះកន្លោង ថ្វាយបង្គំប្រណម្យទូលថា បពិត្រព្រះមេដ៏មានគុណធ្ងន់ប្រសើរអើយ តើអ្នកមានមាសដឹងអើយ? ខ្ញុំនឹងចង់ឲ្យទានបន្តិចហ: ។ សម្ដេចព្រះវររាជមាតាឮហើយ មានព្រះបន្ទូលថា តាត បិយបុត្តក ម្នាលកូនស្ងួនសម្លាញ់មាសម្ដាយអើយ នឹងក្រអ្វីមាសនោះឡើយ ព្រះនាងទេវីមានព្រះបន្ទូលម្ល៉ោះហើយ ព្រះនាងយកមាស ១ ពាន់តម្លឹង ដាក់លើព្រះហស្តព្រះពោធិសត្តព្វដ៏កាលនោះហោង ។ នាកាលព្រះពោធិសត្វចាកចេញអំពីព្រះមាតុទរនោះ បានទទួលយកមាសអំពីព្រះកន្លោង ហើយព្រះអង្គឲ្យទៅជាទានមួយរំពេចនោះឯង រីឯព្រះបរម ពោធិសត្វកាលចាក

Websites: WatKhemaraRatanaram.org or WatKhmers.org

ចេញអំពីព្រះឧទរបវរព្រះកន្លោង ហើយមានព្រះបន្ទូលនឹងព្រះវររាជមាតានោះមាន ៣ ដង គឺកាលជាព្រះមហោសថម្តង កាលជាព្រះវេស្សន្តរនេះម្តង កាលជាព្រះសិទ្ធាថិនោះម្តង ។ បពិត្រអើយ នាកាលសម័យនឹងសន្មតកត់ព្រះនាម ព្រះបរមពោធិសត្វនោះ ហេតុនិមិត្តព្រះអង្គកើតនៅនាកណ្តាលផ្លូវឈ្មួញកូវ អស់ព្រះញាតិផងទាំងឡាយ ក៏សន្មតព្រះនាមករណ៍ ចំរើនព្រះពរហៅថា «ព្រះវេស្សន្តរកុមារ» ។

តេន វុត្តំ ហេតុនោះ លុះព្រះអង្គបានត្រាស់ហើយ មានព្រះបន្ទូលនឹងព្រះមហាសារីបុត្តត្ថេរ សូត្រជាបទព្រះគាថាដូច្នេះថា ៖

ន មយ្ហំ មត្តិកំ នាមំ នបិ បេតិកសម្ភវំ
ជាតោម្ហិ វេស្សវីថិយា តស្មា វេស្សន្តរោ អហុន្តិ ។

សារីបុត្ត ហៃបាសារីបុត្តអើយ នាកាលតថាគតកើតមកបានឈ្មោះ ថាព្រះវេស្សន្តរនោះ មិនមែនជាប់ដោយព្រះនាមមាតាបិតាឡើយ ដោយហេតុតែតថាគតកើតនាកណ្តាលផ្លូវឈ្មួញធំ ក៏អស់ព្រះញាតិផង គេមកសន្មតកត់ព្រះនាមតថាគតថា «ព្រះមហាវេស្សន្តរកុមារ» ដូច្នេះហោង ។ នាកាលថ្ងៃព្រះអង្គចាកចេញ អំពីព្រះមាតុទរ

Websites: WatKhemaraRatanaram.org or WatKhmers.org

បវរថ្លៃនៃព្រះកន្លោងព្រះមាតានោះ ឮដ៏កាលនោះ មានដំរីញីមួយ មានប្រក្រតីតែងតែដើរឮដ៏កណ្តាលអាកាស នាំកូនដំរីឈ្មោលមួយមក ថ្វាយព្រះបរមពោធិសត្វ ហើយមេដំរីនោះក៏ហោះទៅបាត់វិញទៅ ។ ដំរីនោះកើតមានជាបច្ច័យនៃព្រះមហាសត្វ ទើបអស់មហាជនផងទាំងឡាយសន្មតនាមដំរីនោះថា «បច្ច័យនាគេន្ទ្រ» ហោង ។

រាជា មហាសត្តស្ស អតិឃីឃាទិទោសវជ្ជិតា អលម្ពុត្ត-ឌិយោ មជ្ជវទីភយោ ចតុសដ្ឋីជាតិយោ ធាបេសិ ។ ទើបមហា-ក្សត្រាធិរាជ ស្តេចឲ្យស្រាវជ្រើសរើសរកមេនំឲ្យបាន ៦៤ នាក់ វៀរលែងនូវទោសជាដើម គឺខ្ពស់ពេក ទាបពេក ទោះបីដោះសណ្តាយក៏ស្តេចពុំឱ្យយកឡើយ ឲ្យយកតែដោះក្បំសមនូវរូបនោះល្អប្រពៃ ទើបព្រះអង្គឲ្យយកមកជាមេនំ បំរើព្រះពោធិសត្វនោះ ហើយស្តេចឱ្យមេនំទៅអស់ក្មេងទាំង ៦ ម៉ឺននោះមួយ ៗ ម្នាក់សព្វគ្រប់ទាំង ៦ ម៉ឺន ។ លុះព្រះពោធិសត្វចំរើនធំឡើង ទើបព្រះមហាក្សត្រាធិរាជ ស្តេចឱ្យប្រដាប់នូវគ្រឿងអលង្ការ មានតម្លៃ ១ សែនតម្លឹង ឲ្យព្រះបរមពោធិ-សត្វ ៗ ទ្រង់បន្តិចហើយ ស្តេចដោះឲ្យទៅជាទានមេនំផងទាំងឡាយ

Websites: WatKhemaraRatanaram.org or WatKhmers.org

ហើយព្រះមហាក្សត្រាធិរាជ ទ្រង់ឲ្យប្រដាប់ថ្វាយដល់ព្រះបរមពោធិសត្វវិញទៀត ព្រះអង្គទ្រង់បន្តិចហើយ ស្ដេចដោះប្រទានទៅមេនំផងវិញទៀត ។ នាកាលព្រះអង្គនៅក្មេងនៅឡើយនោះ តែងនឹងដោះគ្រឿងប្រដាប់ឲ្យទៅជាទានមេនំផងទាំងឡាយរៀងៗ តទៅជាគំរប់ ៩ ដងហោង ។

សោ អដ្ឋវស្សិកកាលេ បន ចាសាទវរគតោ សយនបិដ្ឋេ និសិន្នោ ចិន្តេសិ ។ លុះព្រះអង្គចំរើនធំឡើង បានព្រះជន្ម ៨ ព្រះវស្សាហើយ ស្ដេចឡើងទៅលើប្រាសាទវ័ត្ន គង់លើខ្នងកម្រាលជាប្រដាប់ដ៏ប្រសើរ កើតព្រះតម្រិះក្នុងព្រះរាជហឫទ័យ នឹងចង់ឲ្យអជ្ឈត្តិកទាន គឺទានក្នុងខ្លួនព្រះអង្គឯង ថានរអ្នកឯណាមួយ ជាស្មូមយាចកមកសូមក្បាលអញក្តី ទោះវាមកសូមភ្នែកអញក្តី ទោះវាសូមថ្លើមអញក្តី សាច់ស្ងួតឈាមអញក្តី ក៏អញនឹងកាត់ក្បាលឆ្កៀលយកភ្នែក ពុះទ្រូងរូងយកថ្លើម អាវសាច់សម្រក់ឈាម ឲ្យទៅជាទានស្មូមផងទាំងឡាយនោះ ទោះស្មូមឯណាមួយវាមកស្រដីថា នៃព្រះវេស្សន្តរអើយ អ្នកទៅនៅបំរើអញ ក៏អញនឹងលួងលោមអាត្មាអញ ឲ្យទៅ

Websites: WatKhemaraRatanaram.org or WatKhmers.org

នៅជាខ្ញុំបំរើអ្នកនោះហោង ។

តស្សេវ សការំ សរសចិត្តំ ចិន្តេន្តស្ស ចតុជហុតាជិកា- ទ្ធិយោជនសតសហស្សពហលា អយំ មហាបឋវី មត្តវរវារណោ វិយ តជ្ជមានា កម្បិ ។ សិនេរុបព្វតរាជា សុសេជិតវេត្តង្គុរោ វិយ ឱនមិត្វា ជេតុត្តរនគរាភិមុខោ អដ្ឋាសិ ។ កាលនោះ ព្រះអង្គត្រិះរិះក្នុងព្រះរាជហឫទ័យ នឹងឲ្យអជ្ឈត្តិកទាននោះ ក៏កើតជាអស្ចារ្យក្រៃពេក រីក្រឡាមហាប្រឹថពីឯងមានកម្រាស់នោះ ២ សែន ដ៏អធិកនីទៅនូវ ៤ ម៉ឺនយោជន៍ ក៏ពុំអាចដើម្បីនឹងទប់ទល់តម្កល់អាត្មាភាពនោះបានឡើយ សឹងដ៏កក្រើករំពើក បញ្ចេញនូវស័ព្ទសម្រែកនោះស្រៀវមហិមាក្រៃពេក មិនប៉ុន្តែម្ល៉ោះសោត រីឯមហាសមុទ្រឯងដ៏មានទឹកនោះ ពុះពោរជោរឡើងរំជិរំជែង បោកបែកផ្កាត្រែង រលករលងមកលើមាត់ច្រាំង រីភ្នំសិនេរុបព៌តរាជនោះសោត សឹងក៏មានកំពូលនោះទន់ល្វន់ល្វាសទៅមក បីដូចចុងដំបងទងផ្តៅ គិតដ៏អ្នកកាត់ចុងដើមបោះទៅក្នុងពពុលភ្លើង ហើយយកមកបោចបកបញ្ឈរឡើង ទន់ល្វន់ល្វាសនោះ មានប្រការដូចម្តេចមិញ រីភ្នំព្រះសិនេរុរាជ នោះក៏ឱនលំទោនឆ្ពោះទៅកាន់

Websites: WatKhemaraRatanaram.org or WatKhmers.org

ជេតុត្តរនគរនោះ មានប្រការដូច្នោះហោង ។ រីបណ្តាភ្នំទាំងពួង សោត សឹងដ៏មានកំពូលនោះរណ្តំគ្នា បន្លឺនូវស័ព្ទឮសូរគឹកកងក្រៃ ពេក ។ រីផ្គរសោតដ៏លាន់ឮស័ព្ទនោះកងរំពង រីផ្លេកបន្ទោរពុំជួកាល សឹងដ៏ដាល ច្រវាត់ចាលចាញ់សម្ភារបារមី នៃព្រះបរមពោធិសត្វព្វដ៏ កាលនោះ ព្រះឥន្ទ្រាធិរាជក៏ទះព្រះហស្តថ្វាយស័ព្ទសាធុការ ទាំងមហា ព្រហ្មក៏ស្លតីថ្វាយជ័យមង្គល រីស័ព្ទកោលាហលក៏កើតប្រាកដដរាប ដល់ព្រហ្មលោកនាយហោង ។

វុត្តម្បិ ចេតំ សេចក្តីនេះសមដូចព្រះពុទ្ធដីកាដែលព្រះអង្គ មានបន្ទូលជាបាទព្រះគាថាដូច្នេះ ៖

យទាហំ ទារកោ ហោមិ ជាតិយា អដ្ឋវស្សិកោ
តទា និសជ្ជ ចាសាទេ ទានំ ទាតុំ វិចិន្តយឹ
ហទយំ ទទេយ្យំ ចក្ខុំ មំសម្បិ រុធីរម្បិ ច
ទទេយ្យំ កាយំ សាវេត្វា យទិ កោចិ យាចយេ មមន្តិ
សភាវំ ចិន្តយន្តស្ស អកម្បិតមសណ្ឋិតំ
អកម្បិ តត្ថ បឋវី សិនេរុវនវដំសកាតិ

Websites: WatKhemaraRatanaram.org or WatKhmers.org

កាលអញតថាគតនៅជាទារក កើតមកបានអាយុ ៨ ខួប អង្គុយគិតនៅក្នុងប្រាសាទ ដើម្បីនឹងឲ្យទានក្នុងវេលាគ្រានោះ ប្រសិនណា បើមានស្មូមមកសូមបេះដូង ភ្នែក សាច់ ស្បែក លោហិត ឬរាងកាយក្តី អញតថាគតក៏នឹងពុះវះកាត់ឲ្យជាទានទាំងអស់ កាលណាអញតថាគត កំពុងគិតត្រិះរិះដូច្នេះ ចិត្តតថាគតឥតមានរំភើបញាប់ញ័ររន្ធត់តក់ស្លុតឡើយ ក្នុងសម័យនោះ ផ្ទៃផែនដីដែលមានភ្នំសុនេរុរាជនិងព្រៃហេមពាន្តជាគ្រឿងប្រដាប់ ក៏កក្រើកញាប់ញ័រជាចលាចលអស្ចារ្យ ។

ពោធិសត្តោ សោឡសវស្សិកកាលេយេវ សព្វសិប្បានំ និប្ផត្តិំ ចាបុណិ ។ លុះព្រះបរមពោធិសត្វចំរើនឡើងបានព្រះជន្ម ១៦ ព្រះវស្សា ព្រះអង្គរៀនចប់ត្រៃវេទផងទាំងឡាយ ឥតទើសទាល់សល់នឹងប្រាជ្ញាទិព្វវិសេសនោះឡើយ ។ អណ្តាប់នោះ សម្តេចព្រះវររាជបិតាទ្រង់មានព្រះបំណង នឹងព្រះរាជទានរាជ្យទៅព្រះពោធិសត្វ ទ្រង់ប្រឹក្សានឹងព្រះនាងសុបារសុប្បតីទេវីស្រេច ហើយស្តេចឲ្យទៅនាំនាងខត្តិយកញ្ញាមួយឈ្មោះ នាងមទ្រីទេវី សោភាអំពីមាតុលនគរ ដ៏ជាព្រះ

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រះរាជត្រកូល នៃសម្ដេចមទ្រីរាស្ត្រមកហើយ ទើបព្រះមហាក្សត្រតម្កល់ព្រះនាមមទ្រីទេវីនេះ ឲ្យជាអយ្យិអគ្គមហេសី ជាអធិបតីនៃអស់ស្ត្រីទាំង ១ ម៉ឺន ៦ ពាន់នោះ ហើយអភិសេកព្រះបរមពោធិសត្វឲ្យសោយរាជ្យសម្បត្តិ ឋិតស្នងគ្រងព្រះរាជប្រពៃណី តអំពីសម្ដេចព្រះវររាជបិតាធិរាជនោះឯងហោង ។

មហាសត្តោ រជ្ជេ បតិដ្ឋិតកាលតោ បដ្ឋាយ ទេវសិកំ ទេវសិកំ ឆ សតសហស្សានិ វិស្សជ្ជេន្តោ មហាទានំ បវត្តេសិ ។ ចាប់អំពីកាលព្រះបរមពោធិសត្វ មហាបុរសរ័ត្នវិសេស បានសោយរាជសម្បត្តិហើយ ក៏ស្ដេចចាយព្រះរាជទ្រព្យ ឲ្យជាទានអស់ស្មូមយាចកអ្នកកំសត់ទុគ៌តទាំងឡាយ ក្នុងមួយថ្ងៃៗ នោះ ប្រាំមួយសែនតម្លឹង គ្រប់សព្វសាលាទាំង ៦ នោះ ។ លុះយូរលង់បន្តិចទៅក្ដីសម្ដេចព្រះភគវតីមទ្រីទេវី ទ្រង់គភ៌ខែ ១០ គ្រប់បរិបូណ៌ ពុំយូរឡើយព្រះនាងប្រសូតព្រះរាជបុត្រមួយបរិសុទ្ធកន្លង រីពពួកព្រះញាតិទាំងឡាយ ទទួលព្រះរាជកុមារនឹងបណ្ដាញមាស ហេតុនោះហោង ក៏សន្មតព្រះនាមហៅថា «ជាលីកុមារ» ។ លុះជាលីកុមារចេះ

ចាប់សៀរដើរទងទោងឈោងវារបន្តិច ៗ ហើយកូវ ព្រះនាងប្រសូត ព្រះរាជបុត្រីមួយវិញទៀត អស់ព្រះញាតិផងទាំងឡាយនាំគ្នាទទួល ព្រះរាជបុត្រីនោះនឹងស្បែកខ្លាឃ្មុំរាយផ្កាយ សឹងមាស ហេតុនោះឯង ទើបសន្មតកត់ហៅថា «នាងក្រស្នាកុមារី» ដូច្នេះ ។

មហាសត្តោ មាសស្ស ឆក្ខត្តុំ អលង្កតហត្ថិខន្ធវរគតោ ឆ ទានសាលាយោ ឱលោកេសិ ។ ព្រះមហាសត្វ ព្រះអង្គឡើងគង់លើ ដំរីរ័ត្នមង្គលដ៏ប្រសើរ ស្តេចទៅទតសាលាទានទាំង ៦ ក្នុង ១ ខែ ៦ ដង សព្វៗ ខែរៀងទៅ ។

តទា កលិង្គរដ្ឋេ ទុព្ភិក្ខា អហោសិ ។ ឰដ៏កាលនោះ មានស្រុកស្តេចព្រាហ្មណ៍មួយ ឈ្មោះកលិង្គរាស្ត្រ នៅឰដ៏ទុរ្ភិគ្រាម កើតទុរ្ភិក្សរាំងភ្លៀងអត់បាយ រីទន្សាយសោតសឹងក៏កាត់ស្រូវ ដង្កូវ រោមផ្លែពេញទាំងស្រែ ឯស្រូវនោះក៏វាស្អុកស្លាប់អស់ មិនមានសល់ ដល់តិចឡើយ អស់មហាជនផងទាំងឡាយ សឹងកើតជាចោរខ្មួយ អស់ហោង ហើយកើតជាកោលាហលរវល់ក្នុងព្រះនគរ ក្រៅព្រះនគរ ឥតសុខសប្បាយដល់តិចឡើយ ទើបអស់នាម៉ឺនមុខមន្ត្រី សេនាបតី

Websites: WatKhemaraRatanaram.org or WatKhmers.org

រាជបណ្ឌិត អាមាត្យ កវីអ្នកប្រាជ្ញ រាជបុរោហិត ព្រាហ្មណ៍ព្រឹទ្ធ ផងទាំងពួង បបួលគ្នាជំនុំនៅនាកណ្ដាលមុខព្រះលានហើយ ទើបក្រាបបង្គំទូលព្រះមហាក្សត្រាធិរាជថា បពិត្រព្រះសម្មតិទេពក្សត្រថ្លៃប្រសើរអើយ ឥឡូវនេះវាកើតកោលាហលវរល់ដូច្នេះ តើយើងខ្ញុំនឹងធ្វើដូចម្ដេច ក៏នឹងបានភ្លៀងបង្អុរចុះមកបាន សូមទានព្រះមេត្តាប្រោស ព្រះអង្គគិត (រកឧបាយ) ក៏បានអេះ ថាបើព្រះអង្គមិនទ្រង់គិតហើយ អស់មហាជនផងទាំងឡាយ មុខជាអត់បាយស្លាប់អស់មិនទេឡើយ ។

តំ សុត្វា រាជា ភឹ តាតាតិ វុត្តេ ព្រះមហាក្សត្រាធិរាជទ្រង់ព្រះសណ្ដាប់ហើយ មានព្រះបន្ទូលថា ម្នាលអ្នកទាំងឡាយអើយថាបើដូច្នោះ រង់ចាំអញសិនឲ្យបាន ៧ ថ្ងៃ សូមភ្លៀងនោះលមើល ។ ព្រះមហាក្សត្រាធិរាជមានព្រះបន្ទូលម្ល៉ោះហើយ ឲ្យដំណើរអស់មុខមន្ត្រីផងទាំងឡាយ ទៅកាន់ឋានលំនៅអាត្មាទីទៃៗ នោះរៀងខ្លួនហោង ។ ឯក្រោយនោះឯង ព្រះមហាក្សត្រាធិរាជ ព្រះអង្គឡើងទៅគង់លើប្រាសាទវ័ត្តដ៏ប្រសើរ ទ្រង់នូវព្រះពស្ត្រសបរិសុទ្ធមកស្ដាយ

Websites: WatKhemaraRatanaram.org or WatKhmers.org

ឆៀងប្រពៃ ហើយតាំងសីលឧបោសថ ៧ ថ្ងៃនោះក្តី សូម្បីនឹងមានភ្លៀងស្រក់ចុះមក ១ តំណក់នោះក៏គ្មានឡើយ ។ អស់មុខមន្ត្រីផងទៅជំនុំគ្នាវិញទៀត ទើបព្រះមហាក្សត្រាធិរាជ មានព្រះបន្ទូលថា ម្នាលអ្នកទាំងឡាយអើយ ឥឡូវនេះអញចាំសីលឧបោសថនោះ ជាគំរប់ ៧ ថ្ងៃ ថ្ងៃនេះហើយ សូម្បីនឹងមានភ្លៀងធ្លាក់ចុះមកដល់ ១ តំណក់នោះក៏គ្មានឡើយ ដូច្នេះយើងនឹងគិតធ្វើដូចម្តេចតអំពីនេះទៅទៀត ? ទើបអស់មុខមន្ត្រីផងទាំងឡាយ ក្រាបបង្គំទូលថា សូមទានព្រះមេត្តាប្រោស យើងខ្ញុំអម្ចាស់បានដឹងឮថា ព្រះបាទស្រីវេស្សន្តរជាព្រះរាជបុត្រព្រះបាទស្រីសញ្ជ័យ នៅនាជេតុត្តរនគរសព្វថ្ងៃនេះ តែងនឹងយកមាសប្រាក់ឲ្យទានស្មូមយាចកផងទាំងឡាយ មិនដែលដាច់ឡើយ យើងខ្ញុំឮថា ព្រះអង្គមានដំរីរ័ត្នមង្គលមួយឈ្មោះបច្ច័យនាគេន្ទ្រ ។ រីឯដំរីនោះសោត ថាបើដូចដល់ទៅឋានឯណាៗ ហើយភ្លៀងក៏តែងបង្អុរធ្លាក់ចុះក្នុងទីនោះ ។ រីស្រូវ អង្ករ សណ្តែក ល្ងនោះក៏កើតមានឡើងប្រាកដ ទាំងមាសប្រាក់កែវកង សម្បត្តិ សម្ប្សូរសោតក៏កើតមានឯងច្រើន ។ សូមទ្រង់ព្រះមេត្តាប្រោស មានតែព្រះអង្គ

ប្រើព្រាហ្មណ៍ទៅសូមដំរីនោះ នាំយកមកឥឡូវនេះហោង ។ ព្រះមហាក្សត្រទ្រង់ព្រះសណ្ដាប់ហើយ មានព្រះរាជហឫទ័យនោះត្រេកអរក្រៃពេក ទើបស្រាវជ្រើសរើសអស់ព្រាហ្មណ៍ផងទាំងឡាយនោះបាន ៨ នាក់ ។ **តេសំ ជាមានិ** រីឈ្មោះព្រាហ្មណ៍ទាំង ៨ នាក់នោះ មួយឈ្មោះរាមព្រាហ្មណ៍ មួយឈ្មោះធជព្រាហ្មណ៍ មួយឈ្មោះលក្ខណព្រាហ្មណ៍ មួយឈ្មោះសុជាតព្រាហ្មណ៍ មួយឈ្មោះយញ្ញព្រាហ្មណ៍ មួយឈ្មោះសុយាមព្រាហ្មណ៍ មួយឈ្មោះសុជាតមន្តព្រាហ្មណ៍ មួយឈ្មោះកោណ្ឌញ្ញព្រាហ្មណ៍ ព្រះមហាក្សត្រាធិរាជមានព្រះបន្ទូលផ្ដាំ ដោយនូវដំណើរនោះស្រេចហើយ ឲ្យដំណើរព្រាហ្មណ៍ទាំង ៨ នាក់នោះទៅហោង ។

**អថ តេ ព្រាហ្មណា អនុបុព្វេន ជេតុត្តរនគរំ បត្វា ធានគ្គេ ភត្តំ ភុញ្ជិត្វា** ។ ព្រាហ្មណ៍ទាំង ៨ នាក់នោះ ដើរទៅតាមអណ្ដាប់អណ្ដោយទៅដល់នគរជេតុត្តរនោះ ព្រាហ្មណ៍ហូបបាយល្ងាចនៅសាលាទាន ហើយដេកសម្រាន្តនៅនាឋាននោះ នាកាលព្រាហ្មណ៍នឹងដេកនោះ មកគិតពិចារណានឹងគ្នាថា ម្នាលគ្នាយើងអើយ

Websites: WatKhemaraRatanaram.org or WatKhmers.org

មានតែយើងយកល្អងធូលីដីខ្សាច់ លាបស្រឡាបអស់ទាំងខ្លួនយើង នោះ ទើបព្រះអង្គទតរមិលមើលមកយើង ស្គាល់ជាក់ថាព្រាហ្មណ៍ ព្រាហ្មណ៍គិតនឹងគ្នាម្ល៉ោះហើយ ក៏ដេកលក់ស្រមុកខី ៗ ខុរ ៗ ដរាប ដល់ថ្ងៃហោង ។ បពិត្រអើយ លុះព្រឹកព្រហាមឡើងនោះឯង ព្រះបាទស្រីវេស្សន្តរ ព្រះអង្គស្រង់ជម្រះស្រេចហើយ ទើបសោយនូវ ភោជនាហារត្រកាល មានឱជារសពីសាផ្សេងៗ ទើបព្រះអង្គទ្រង់ គ្រឿងប្រដាប់ សម្រាប់ប្រពៃស្រេចហើយនៃ ស្ដេចឡើងគង់លើបា ដំរីរ័ត្នមង្គលប្រសើរ ស្ដេចលីលាទៅទតសាលាទានទាំង ៦ នោះ ស្ដេចចែកចាយព្រះរាជទ្រព្យព្រះរាជទានស្មូមយាចកផងទាំងឡាយ ។ រីព្រាហ្មណ៍ទាំង ៨ នាក់នោះ យល់ស្មូមផងទទួលយកទាននោះឆោ ឡោចង្អៀតទាំងសាលា នឹងចូលទៅសូមដំរីបច្ច័យនាគេន្ទ្រ ឰដ៏ឋាន នោះពុំបានឡើយ ហើយបបួលគ្នាដើរទៅកាន់សាលាទានឯត្បូង ឈរ លើដំបូកបានបន្និចកូវ ព្រះមហាក្សត្រាធិរាជស្ដេចបរដំរីទៅទតសាលា ទាន ឰដ៏ទ្វារឯត្បូងនោះ ហើយព្រាហ្មណ៍ទាំង ៨ នាក់នោះ រមិលមើល ទៅយល់ព្រះមហាក្សត្រាធិរាជ ក៏នាំគ្នាលើកដៃដាក់លើសិរសា ក្រាប

Websites: WatKhemaraRatanaram.org or WatKhmers.org

បង្គំទូលសេចក្តីដូច្នេះថា ៖

ជយតុ ភវំ ជយតុ ភវំ វេស្សន្តរោ ។ សូមព្រះបាទស្រីវេស្សន្តរ ដ៏ជាមហាក្សត្រប្រសើរ ព្រះអង្គមានជ័យជំនះ ព្រះអង្គមានជ័យជំនះឈ្នះអស់សត្រូវផងទាំងពួង ។ ព្រះមហាក្សត្រស្តេចទតយល់ព្រាហ្មណ៍ទាំ ៨ នោះហើយ មានព្រះបន្ទូលដណ្តឹងសួរ ជាបាទព្រះគាថាដូច្នោះថា ៖

បរុឡ្ហកច្ឆនខលោមា  បង្កទន្តា រជស្សិរា
បគ្គយ្ហ ទក្ខិណំ ពាហុំ  កឹ មំ យាចន្តិ ព្រាហ្មណាតិ

ម្នាលប្រស្តែងព្រាហ្មណ៍ អើយអញពិតពិលរមិលមើលទៅប្រស្តែងនេះហើយ យល់អាក្រក់អ្វីមាល្បាយអេះ សឹងប្រឡាក់នូវផង់ធូលីដីខ្សាច់ ដ៏មានធ្មេញស ប្រស្តែងលើកនូវដៃស្តាំដាក់លើក្បាលហើយពោលដូច្នោះថា ជយតុ ភវំ ជយតុ ភវំ នោះតើប្រស្តែងមានបើចង់សូមទ្រព្យអ្វីអំពីអញហះ? ព្រាហ្មណ៍ទាំង ៨ នាក់នោះ ឮហើយក្រាបថ្វាយបង្គំប្រណម្យទូលជាបាទគាថាដូច្នេះថា ៖

រតនំ ទេវ យាចាម  សិវីនំ រដ្ឋវឌ្ឍនំ

Websites: WatKhemaraRatanaram.org or WatKhmers.org

ឧបាហិ បវរំ ជាតំ ឦសានត្តំ ឧរុឡ្ហវត្តិ ។

បពិត្រព្រះនារាយណ៍នរបតី ស្រីសម្មតិទេព មហារាជប្រសើរអើយ យើងខ្ញុំមកសូមដំរីរ័ត្នប្រសើរ តែងនឹងចំរើនសិរីសួស្តីអ្នកស្រីពិរាស្រ្តផងទាំងពួង ដ៏មានភ្លុកស្តាំនោះងទន្ទាំកំពុងពេញកម្លាំង ដ៏មានចាមរនោះល្តាយល្តងរាំងគន្លងបោសព្រះធរណី សូមព្រះអង្គព្រះរាជទានមកយើងខ្ញុំព្រះអង្គហោង ។

តំ សុត្វា មហាសត្តោ អហំ សីសមាឌី កាត្វា អជ្ឈត្តិកទានំ ទាតុកាមេម្ហិ ។ ព្រះមហាក្សត្រ ស្តេចស្តាប់ពាក្យព្រាហ្មណ៍ហើយ ព្រះអង្គទ្រង់ព្រះចិន្តាពិចារណាថា អញនៅសព្វថ្ងៃនេះ គិតតែនឹងចង់ឲ្យអជ្ឈត្តិកទាន គឺទានក្នុងខ្លួនអញ ក៏ឥឡូវនេះព្រាហ្មណ៍សូមដំរីបច្ច័យនាគេន្ទ្រនេះហៅថា ពាហិរកទាន ក្រៅខ្លួនអញក៏អញនឹងឲ្យឥឡូវនេះឯង ។ ព្រះបរមពោធិសត្វ ទ្រង់ព្រះចិន្តាពិចារណា នូវប្រការអម្បាលណោះហើយ ទើបមានព្រះបន្ទូលទៅនឹងព្រាហ្មណ៍ទាំង ៨ នោះ សូត្រជាបាទព្រះគាថាដូច្នេះថា ៖

ឧបាមិ ន វិកម្បាមិ យំ មំ យាចន្តិ ព្រាហ្មណា

Websites: WatKhemaraRatanaram.org or WatKhmers.org

បភិន្នំ កុញ្ជរំ ទន្តឹ ឱបគុយ្ហំ គជុត្តមន្តិ ។

ហៃប្រស្តែងព្រាហ្មណ៍អើយ អញនៅសព្វថ្ងៃនេះ ពុំមានចិត្តរន្ធត់ទៅដោយចិត្តកំណាញ់ឡើយ មួយសោតអញនៅសព្វថ្ងៃនេះ ពុំមានសំណល់សំចៃលាក់ នូវទ្រព្យល្អអ្វីមួយនឹងស្ងួមនោះ ឥតអង្គឹមានឡើយ ឥឡូវនេះ ប្រស្តែងមកសូមដំរីមង្គលដ៏ជាដំរីឧត្តម សមជារាជពាហនៈដ៏ប្រសើរអំពីអញ អញនឹងប្រទានឲ្យប្រស្តែងឥឡូវនេះហោង។

តេន វុត្តំ ហេតុនោះហោង ព្រះអង្គបានត្រាស់ហើយព្រះអង្គមានព្រះបន្ទូលនឹងព្រះមហាសារីបុត្តត្ថេរថា ៖

ហត្ថិក្ខន្ធតោ ឱរុយ្ហ រាជា ចាគាធិមានសោ

ព្រាហ្មណានំ អទា ទានំ សិវីនំ រដ្ឋវឌ្ឍនោតិ ។

ហៃបាសារីបុត្តអើយ កាលនោះ ព្រះបាទស្រីវេស្សន្តរបរមក្សត្រតែងមានព្រះរាជហឫទ័យសទ្ធាជ្រះថ្លា ទ្រង់ព្រះរាជទានដំរីបច្ច័យនាគេន្ទ្រស្រេចហើយ ស្តេចចុះអំពីកដំរីរ័ត្នមង្គល ទ្រង់ប្រទក្សិណ ៣ ជុំហើយស្តេចទតមើលឋានឯណា ពុំទាន់ប្រដាប់សព្វគ្រប់មិញ ព្រះអង្គក៏ឲ្យប្រដាប់បំពេញអស់ឋានទាំងនោះ ឲ្យពេញបរិបូណ៌ រួចទ្រង់មាន

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រះបន្ទូល ហៅពួកព្រាហ្មណ៍ទាំងអស់នោះឲ្យចូលមក ហើយស្ដេចចាប់ប្រមោយដំរីវ័ត្ន មានឧបមាបីដូចជាកម្រងផ្កាប្រាក់ ស្ដេចដាក់លើដៃព្រាហ្មណ៍ហើយស្រេច ស្ដេចយកនូវទឹកកុណ្ឌីមាសដ៏ពេញនីទៅនូវទឹកអប់ ត្រឡប់នូវគន្ធពិដោរ ព្រះអង្គទ្រង់ច្រូចទឹកលើដៃព្រាហ្មណ៍ ហើយព្រះរាជទានដំរីវ័ត្នមង្គលនោះទៅព្រាហ្មណ៍ទាំងនោះហោង ។

ហៃបាសារីបុត្តអើយ រីឯគ្រឿងប្រដាប់ជើងដំរីទាំង ៤ នោះសោត មានតម្លៃ ៤ សែនតម្លឹង រីគ្រឿងប្រដាប់សម្រាប់សងខាងជើងដំរីនោះសោត មានតម្លៃ ២ សែនតម្លឹង រីសំពត់រាយផ្កាយមាសពាសព្វដ៏ផ្ទៃដំរីនោះសោត មានតម្លៃ ១ សែនតម្លឹង រីឯបណ្ដាញវ័ត្នទាំង ៣ ជាគ្រឿងប្រដាប់រំយោលលើខ្នងដំរីនោះ មានតម្លៃ ៣ សែនតម្លឹង រីគ្រឿងប្រដាប់ផ្ដាល់ដំរីទាំងសងខាងនោះ មានតម្លៃ ២ សែនតម្លឹង រីសំពត់រត្តកម្ពលពាសក្រាលលើខ្នងដំរីនោះ មានតម្លៃ ១ សែនតម្លឹង រីគ្រឿងប្រដាប់ពោងដំរីនោះ មានតម្លៃ ១ សែនតម្លឹង រីមណីវ័ត្នទាំង ៣ ប្រដាប់ចង្កាដំរីនោះ មានតម្លៃ ៣ សែនតម្លឹង ឯគ្រឿងប្រដាប់ទាំងសងខាងត្រចៀកដំរីនោះ មានតម្លៃ ២ សែនតម្លឹង

រីគ្រឿងប្រដាប់ភ្លុកដំរីទាំងសងខាងនោះ មានតម្លៃ ២ សែនតម្លឹង រីមណីរ័ត្នជាគ្រឿងប្រដាប់ប្រមោយដំរីនោះ មានតម្លៃ ១ សែន តម្លឹង រីមណីរ័ត្នប្រដាប់កន្ទុយដំរីនោះ មានតម្លៃ ១ សែនតម្លឹង រីមណីរ័ត្នប្រដាប់ជើងជណ្ដើរ តែងនឹងឡើងដំរីនោះ មានតម្លៃ ១ សែនតម្លឹង រីខ្ទះដណ្ដាំបាយឲ្យដំរីសព្វថ្ងៃនោះ មានតម្លៃ ៩ តម្លឹង រីនឹងស្រដីអស់ទ្រព្យគ្រឿងប្រដាប់សម្រាប់ដំរីនោះ មកផ្សំអស់ទាំងអម្បាលនោះ ត្រូវជាមាស ២ លាន និង ៤ សែនតម្លឹងហោង ។ ឯទ្រព្យក្រៅអំពីនោះទៅ រីមណីរ័ត្នប្រដាប់កង្វេរនោះក្ដី រីមុក្តារ័ត្នប្រដាប់ខ្សែរំយោលស្វេតច្ឆ័ត្រសម្រាប់ដំរីនោះក្ដី សឹងមានតម្លៃនឹងកាត់ថ្លៃនោះពុំបានឡើយ ព្រះអង្គឲ្យទានមិនប៉ុន្តែដំរី និងគ្រឿងប្រដាប់នោះឡើយ ហើយស្ដេចប្រទានអស់ទាំងពេទ្យហ្ម ទ្រមាក់ រក្សាទាំង ៥០០ ស្ដេចឲ្យទៅជាទាន មួយអន្លើនឹងដំរីនោះឯង ។ កាលនោះសេចក្ដីអស្ចារ្យកើតមានប្រាកដ ទាំងក្រឡាមហាប្រឹថពីឯង ក៏កក្រើកជាដើម ដូចន័យដែលបានពោលរួចមកហើយ ។

តមត្ថំ បកាសេន្តោ សត្ថា អាហ ។ រីអាថ៌ធម៌ឯណា

Websites: WatKhemaraRatanaram.org or WatKhmers.org

ពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គមានព្រះបន្ទូលនឹងភិក្ខុផងទាំឡាយ សូត្រជាបាទព្រះគាថាដូច្នេះ ៖

តជាសិ យំ ភីសនកំ តជាសិ លោមហំសនំ
ហត្ថិនាគេ បជិន្នម្ហិ មេទនី សមកម្បថ ។
តជាសិ យំ ភីសនកំ តជាសិ លោមហំសនំ
ហត្ថិនាគេ បជិន្នម្ហិ ខុភិត្ថ នគរំ តជា
សមាកុលំ បុរំ អាសិ ឃោសោ ច វិបុលោ មហា
ហត្ថិនាគេ បជិន្នម្ហិ សិវីនំ រដ្ឋវឌ្ឍនេតិ ។

ភិក្ខវេ ហៃភិក្ខុផងទាំងឡាយអើយ នាកាលព្រះវេស្សន្តរព្រះរាជទានដំរីបច្ច័យនាគេន្ទ្រ ទៅព្រាហ្មណ៍ទាំង ៨ នាក់នោះ ក៏កើតអស្ចារ្យជាពន្លឹកមុខគួរខ្លាច នាំឲ្យព្រឺព្រួចអស់ទាំងលោមា អស់ទាំងអ្នកនគរក៏ភ្ញាក់ផ្អើលវរវីក សូរស័ព្ទអ៊ឹកធឹកលាន់ឮរំពងជាអស្ចារ្យក្រៃលែង ក្នុងកាលដែលព្រះវេស្សន្តរព្រះរាជទានដំរីដ៏ប្រសើរ តែងធ្វើនូវសេចក្តីចម្រើនដល់អ្នកស្រុកស្រីពិរាស្ត្រឮដ៏កាលនោះហោង។

ព្រាហ្មណា ភិរ នគ្គិណាទ្វារេ ហត្ថឹ លភិត្វា ហត្ថិបិដ្ឋ និសីទិត្វា មហាជនបរិវុតា នគរមជ្ឈេន ចាយឹសុ ។

កាលនោះព្រាហ្មណ៍ទាំង ៨ នាក់ មកសូមដំរីបច្ច័យនាគេន្ទ្រនៅទ្វារឯត្បូងនោះបានហើយ ក៏នាំគ្នាឡើងជិះអំពីក្បាលរៀងទៅដល់កន្ទៀ បរចេញទៅមួយអន្លើនូវអស់បរិវារផងទាំងឡាយប្រមាណ ៥០ នាកណ្តាលព្រះនគរនោះឯង ។ រីអស់មហាជនរមិលមើលទៅយល់ដំរីរ័ត្នមង្គលហើយ ក៏ស្រដីទៅវិញទៅមកកាន់គ្នាថា អ្នកទាំងឡាយអើយ ព្រាហ្មណ៍នេះវាបានដំរីអំពីឯណាបរទៅនោះអេះ អ្នកខ្លះរត់ទៅស្រែកដណ្តឹងសួរថា វើយព្រាហ្មណ៍ ប្រស្តែងបានដំរីនោះមកអំពីណា ក៏បរទៅព្រងើយដូច្នោះហ៎ ? រាមព្រាហ្មណ៍ស្តាប់ហើយឆ្លើយថា ប្រស្តែងដណ្តឹងធ្វើអ្វី ដំរីព្រះស្តែងឬអ្វីហ: ? ដំរីនេះព្រះបាទស្រីវេស្សន្តរព្រះអង្គឲ្យទានយើង ៗ យកជិះបរទៅឯងអេះ ងារការអ្វីនឹងប្រស្តែង ក៏ប្រស្តែងមកដណ្តឹងហ៊ឹះ ។ អ្នកខ្លះបូញមាត់ បត់ដុំដៃបង្ហាញទៅថា នែប្រស្តែងដណ្តឹងរកដុំដៃដៅខ្នង ឬមួយចង់ស៊ីផ្លែស្រម៉ដៅក្បាលវិញហ: ។ ព្រាហ្មណ៍ស្រដីតែម្លោះហើយ ក៏បរដំរីនោះចេញ

Websites: WatKhemaraRatanaram.org or WatKhmers.org

ទៅដោយទ្វារឯជើងព្រះនគរនោះហោង ។

រីអស់អ្នកនគរផងទាំងឡាយ ហេតុតែទេវតាមកអាគៀស ចិត្តនោះមិញណា ក៏សឹងតែខឹងនឹងព្រះពោធិសត្វនោះមហិមាក្រៃពេក ហើយបប្លូលគ្នាទៅជុំនំនៅនាមុខព្រះលាន ស្រដីនូវពាក្យនោះកងរំពង ឮទៅនាកណ្តាលអាកាស តេន វុត្តំ ហេតុនោះហោង ព្រះអង្គបាន ត្រាស់ប្រាជ្ញាសព្វេជ្ញូតាញាណ ព្រះអង្គមានព្រះបន្ទូលនឹងព្រះមហា សារីបុត្តត្ថេរ សូត្រជាបាទព្រះគាថាដូច្នេះថា ៖

អចេត្ថ វត្តតិ សទ្ទោ តុមុលោ ភេរវោ មហា
ហត្ថិនាគេ បទិន្នម្ហិ ខុភិត្ថ ឆគរំ តទា
អចេត្ថ វត្តតិ សទ្ទោ តុមុលោ ភេរវោ មហា
ហត្ថិនាគេ បទិន្នម្ហិ សិវីនំ រដ្ឋវឌ្ឍនេតិ ។

ថាហៃបាសារីបុត្តអើយ ឮដ៏កាលនោះ រីអស់អ្នកនគរផង ទាំងឡាយ គេខឹងនឹងអញតថាគត ត្បិតតែឲ្យទានដំរីមង្គលប្រសើរទៅ ព្រាហ្មណ៍ ហាក់ដូចនឹងរបើករលើង ទាំងព្រះនគរនោះឯងហោង ។ ម្នាលបាសារីបុត្តអើយ នាកាលអញតថាគតប្រទានដំរីមង្គល តែងធ្វើ

Websites: WatKhemaraRatanaram.org or WatKhmers.org

នូវសេចក្ដីចម្រើនដល់អ្នកស្រុកស្រីពិរាស្ត្រ កាលនោះមានសូរស័ព្ទកងរំពងទាំងនគរស្រីពិរាស្ត្រនោះមុខគួរស្លប់ស្លែងជាពន្លឹក ។ គ្រានោះ ពួកអ្នកនគរមានចិត្តខេខឹងនឹងព្រះពោធិសត្វ ព្រោះតែព្រះអង្គព្រះរាជទានដំរីបច្ច័យនាគេន្ទ្រនោះ ទើបនាំគ្នាឡើងក្រាបបង្គំទូលដល់ព្រះបាទស្រីសញ្ជ័យមហារាជដ៏ជាសម្ដេចព្រះវររាជបិតា តេន វុត្តំ ហេតុនោះហោងព្រះអង្គមានព្រះបន្ទូលសូត្រជាបាទព្រះគាថាដូច្នេះថា ៖

ឧគ្គា ច រាជបុត្តា ច　　វេសិយានា ច ព្រាហ្មណា
ហត្ថារោហា អនីកដ្ឋា　　រថិកា បត្តិការកា ។
កេវលោ ចាបិ និគមោ　　សិវិយោ ចាបិ សមាគតា
ទិស្វា នាគំ និយ្យមានំ　　តេ រញ្ញោ បដិវេទយុំ ។
វិធមំ ទេវ តេ រដ្ឋំ　　បុត្តោ វេស្សន្តរោ តវ
កថំ នោ ហត្ថិនំ ទជ្ជា　　នាគំ រដ្ឋស្ស បូជិតំ ។
កថំ នោ កុញ្ជរំ ទជ្ជា　　ឦសាទន្តំ ឧរូឡ្ហវំ
ខេត្តញ្ញុំ សព្វយុទ្ធានំ　　សព្វសេតំ គជុត្តមំ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

បណ្ឌុកម្ពលសញ្ឆន្នំ បភិន្នំ សត្តុមទ្ទនំ
ទន្តិំ សវាលវីជនឹ សេតំ កេលាសសាទិសំ ។
សសេតច្ឆត្តំ សុបត្ថេយ្យំ សាថព្វនំ សហត្ថិបំ
អគ្គយានំ រាជវាហឹ ព្រាហ្មណានំ អទា ធានត្តិ ។

កាលនោះពួកព្រះរាជបុត្រ ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញ ពួក ឈ្មួញ ពួកព្រាហ្មណ៍ ពួកពលដំរី ពួកពលសេះ ពួកពលរថ ពួកពល ថ្មើរជើង រួមទាំងពួកអ្នកនិគមកុដុម្ពីរ ពួកអ្នកស្រុកស្រីពិរាស្ត្រ កាលបានឃើញព្រាហ្មណ៍បរដំរីចេញទៅដូច្នោះ ក៏មកប្រជុំព្រមល្មមជាមួយគ្នា ហើយក្រាបទូលព្រះមហាក្សត្រថា ទេវ បពិត្រព្រះសម្មតិទេពក្សត្រថ្លៃប្រសើរអើយ រីព្រះបាទស្រីវេស្សន្តរ ជាព្រះរាជបុត្ររបស់ព្រះអង្គ មិនបិតដោយនូវគន្លងធម៌ ម្ដេចឡើយក៏មកយកដំរីរ័ត្នមង្គល ដ៏ប្រសើររបស់យើងខ្ញុំ ព្រះរាជទានទៅឱ្យព្រាហ្មណ៍ នាដំរីនោះមានរស្មីភ្លឺផ្លេកៗ មានចាមរល្ហោយល្អងរាំងគន្លងបោសព្រះធរណី ហើយមានភ្លុកឯស្ដាំនោះឯទន្ទាំ អាចញាំញីអស់សត្រូវផង សមនូវស្វេតផ្ឆ័ត្រ

Websites: WatKhemaraRatanaram.org or WatKhmers.org

ជារាជយានដ៏ប្រសើរ តែងនឹងនាំព្រះមហាក្សត្រ ដ៏មានខ្លួននោះស ប្របហែលនឹងភ្នំកៃលាសបពិត ដ៏ជាដំរីប្រសើរ ម្តេចឡើយក៏លើកឲ្យទៅ ជាទានព្រាហ្មណ៍ សមអ្វីនឹងព្រាហ្មណ៍នោះហ៎ុះ ឲ្យទានតែដំរីនោះ ទៅប៉ា ម្តេចឡើយក៏ឲ្យទាំងស្វេតច្ឆ័ត្រ គ្រឿងប្រដាប់ពេទ្យហ្មទាំង ៥០០ នោះទៅផង វាអស់សោះរលីងជាម្តងហោង ។ លុះអ្នកនគរទាំងឡាយ នោះ ក្រាបបង្គំទូលយ៉ាងនេះហើយ ទើបក្រាបទូលសូត្រជាបាទគាថា ដូច្នេះទៀតថា ៖

អន្នំ ចានញ្ច សោ ទជ្ជា វត្ថសេនាសនានិ ច
ឯតំ ខោ ទានបដិរូបំ ឯតំ ខោ ព្រាហ្មណារហំ ។
អយំ តេ វំសរាជានោ សិវីនំ រដ្ឋវឌ្ឍនោ
កថំ វេស្សន្តរោ បុត្តោ គជំ ភាជេតិ សញ្ជយ ។
សចេ ត្វំ ន ករិស្សសិ សិវីនំ វចនំ ឥទំ
មញ្ញេ តំ សហ បុត្តេន សិវិហត្ថេ ករិស្សរេតិ ។

បពិត្រព្រះសម្មតិទេពក្សត្រថ្លៃប្រសើរអើយ ព្រះបាទស្រី វេស្សន្តរនោះ ព្រះអង្គគួរតែព្រះរាជទានបាយទឹក សំពត់អាវសារស្បៃ

Websites: WatKhemaraRatanaram.org or WatKhmers.org

ទីដេក ទីអង្គុយផងទាំងពួង ត្បិតរបស់អស់នេះ សឹងសមគួរដល់ទានទាំងជារបស់ជាសមគួរដល់ពួកព្រាហ្មណ៍ផង ។ បពិត្រព្រះបាទស្រីសញ្ជ័យមហារាជអើយ ព្រះបាទស្រីវេស្សន្តរជាព្រះរាជបុត្ររបស់ព្រះអង្គ បានឡើងគ្រងរាជ្យតព្រះវង្ស តែងទ្រង់ធ្វើសេចក្តីចំរើនដល់អ្នកស្រីពិរាស្ត្រទាំងឡាយ ម្តេចឡើយក៏មកយកដំរីរ័ត្នមង្គល ទៅព្រះរាជទានដល់ព្រាហ្មណ៍ ។ ល្ហឹកណាតែព្រះអង្គមិនព្រមធ្វើតាម ពាក្យអ្នកស្រីពិរាស្ត្រនេះទេ អ្នកស្រីពិរាស្ត្រនឹងធ្វើព្រះអង្គព្រមទាំងព្រះរាជបុត្រ ឲ្យលុះនៅក្នុងកណ្តាប់ដៃគេមិនទេឡើយ ។

ព្រះបាទស្រីសញ្ជ័យមហារាជ ព្រះអង្គទ្រង់ព្រះសណ្តាប់សំដីអ្នកស្រីពិរាស្ត្រអស់នោះហើយ ក៏ទ្រង់ព្រះចិន្តាថា មនុស្សអស់នេះប្រាថ្នានឹងសម្លាប់បាវេស្សន្តរកូនអញ ទើបទ្រង់មានព្រះរាជឱង្ការ សូត្រជាបាទព្រះគាថាដូច្នេះថា ៖

កាមំ ជនបទោ មាសិ រដ្ឋញ្ចាបិ វិនស្សតុ
នាហំ សិវីនំ វចនា រាជបុត្តំ អទូសកំ
បព្វាជេយ្យំ សកា រដ្ឋា បុត្តោ ហិ មម ឱរសោ

Websites: WatKhemaraRatanaram.org or WatKhmers.org

កាមំ ជនបទោ មាសិ    រដ្ឋញ្ចាបិ វិនស្សតុ
នាហំ សិវីនំ វចនា    រាជបុត្តំ អទូសកំ
បព្វាជេយ្យំ សកា រដ្ឋា    បត្តោ ហិ មម អត្រជោ
ន ចាហំ តស្មឹ ទុព្ភេយ្យំ    អរិយសីលវតោ ហិ សោ
អសិលោកោបិ មេ អស្ស    បាបញ្ច បសវេ ពហុំ
កថំ វេស្សន្តរំ បុត្តំ    សត្ថេន ឃាតយាមសេតិ ។

ទោះបើជនបទដែនដីវិនាសបាត់បង់ ទៅយ៉ាងណាក៏ដោយ អញមិនព្រមបណ្ដេញរាជបុត្រ ជាអ្នកឥតទោស ឲ្យចេញចាកដែនដីស្រីពិរាស្ត្រ តាមពាក្យអ្នកស្រីពិរាស្ត្រ ផងទាំងឡាយឡើយ ព្រោះបាវេស្សន្តរជាបុត្រកើតអំពីទ្រូងរបស់អញ កើតអំពីខ្លួនអញ ។ មួយវិញទៀត អញមិនគួរប្រទូសរ៉ាយនឹងបាវេស្សន្តរឡើយ ព្រោះបាវេស្សន្តរនោះជាអ្នកមានសីលដ៏ប្រសើរ ចុះឲ្យអញសម្លាប់បាវេស្សន្តរដោយគ្រឿងសស្ត្រាវុធដូចម្ដេចបាន ។

ពួកអ្នកស្រីពិរាស្ត្របានស្ដាប់ ព្រះរាជតម្រាស់នោះហើយ ទើបនាំគ្នាក្រាបបង្គំទូលព្រះបាទស្រីសញ្ជ័យថា ៖

មា នំ ទណ្ឌេន សត្ថេន　　　　ន ហិ សោ ពន្ធនារហោ
បព្វាជេហិ ច នំ រដ្ឋា　　　　វង្កេ វសតុ បព្វតេ ។

បពិត្រព្រះសម្មតិទេពក្សត្រថ្លៃប្រសើរអើយ រីព្រះបាទស្រីវេស្សន្តរ ដ៏ជាព្រះរាជឱរសរបស់ព្រះអង្គនោះ មិនគួរកាប់នឹងដាវ វាយនឹងដំបង ចងនឹងខ្សែទេ គ្រាន់តែនឹងបណ្តេញឲ្យទៅនៅឯភ្នំគីរីវង្កតបពិត ប៉ុណ្ណោះបានហើយ ។ ព្រះបាទស្រីសញ្ជ័យទ្រង់ព្រះសណ្តាប់ពាក្យអ្នកស្រីពិរាស្ត្រទាំងនោះក្រាបទូលដូច្នោះហើយ ទើបទ្រង់មានព្រះបន្ទូលសូត្រជាបាទព្រះគាថាដូច្នេះថា ៖

ឯសោ ចេ សិវីនំ ធម្មោ　　　　ឆន្ទំ ន បនុទាមសេ
ឥមំ សោ វសតុ រត្តឹ　　　　កាមេ ច បរិភុញ្ជតុ ។
តតោ រត្យា វិវសនេ　　　　សុរិយស្សុគ្គមនំ បតិ
សមគ្គា សិវិយោ ហុត្វា　　　　រដ្ឋា បព្វាជយន្តុ នន្តិ ។

ម្នាលអ្នកទាំងឡាយអើយ នាបាវេស្សន្តរមានទោសនឹងអ្នកទាំងឡាយ នឹងបណ្តេញគាត់ចេញ អញមិនថាអ្វីឡើយ តែសូមឲ្យអ្នកទាំងឡាយអត់ទោសគាត់នារាត្រីនេះសិន ចាំដល់ព្រឹកស្អែកឡើង សឹម

Websites: WatKhemaraRatanaram.org or WatKhmers.org

អ្នកទាំងឡាយមកប្រជុំព្រមល្មមជាមួយគ្នា ហើយបណ្ដេញគាត់ចេញទៅហោង ។ រីព្រះបាទស្រីសញ្ជ័យព្រះអង្គមានព្រះបន្ទូលម្ល៉ោះហើយ ក៏ឲ្យដំណើរពួកអ្នកស្រីពិរាស្រ្ត ទៅកាន់ឋានលំនៅអាត្មាទីទៃៗ។ ឯក្រោយនោះឯង ព្រះអង្គមានព្រះបន្ទូលប្រើរាជអាមាត្យមួយ ឲ្យនាំពត៌មានទៅថ្កានព្រះរាជបុត្រ ។ អាមាត្យនោះទទួលព្រះរាជឱង្ការហើយ ក៏ទៅកាន់ព្រះរាជនិវេសន៍ព្រះបាទស្រីវេស្សន្តរ ក្រាបទូលពត៌មាននោះសព្វគ្រប់ ។

តមត្ថំ បកាសេន្តោ សត្ថា អាហ ។ រីអាចិធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គមានព្រះបន្ទូលនឹងភិក្ខុផងទាំងឡាយ សូត្រជាបាទព្រះគាថាដូច្នេះថា ៖

ឧដ្ឋេហិ កត្តេ តរមានោ  គន្ត្វា វេស្សន្តរំ វទ
សិវិយោ ទេវ តេ កុទ្ធា  នេគមា ច សមាគតា
ឧគ្គា ច រាជបុត្តា ច  វេសិយានា ច ព្រាហ្មណា
ហត្ថារោហា អនីកដ្ឋា  រថិកា បត្តិការកា

Websites: WatKhemaraRatanaram.org or WatKhmers.org

កោរលោ ចាបិ និគមោ   សិវិយោ ចាបិ សមាគតា ។
អស្វា រត្យា វិវសនេ   សុរិយស្សុគ្គមនំ បតិ
សមគ្គា សិវិយោ ហុត្វា   រដ្ឋា បព្វាជយន្តិ តំ ។
ស កត្តា តរមានោវ   សិវិរាជេន បេសិតោ
អាមុត្តហត្ថាភរណោ   សុវត្ថោ ចន្ទនភូសិតោ ។
សីសំ ន្ហាតោ ឧទកេ សោ   អាមុត្តមណិកុណ្ឌលោ
ឧបាគមិ បុរំ រម្មំ   វេស្សន្តរនិវេសនំ ។
តត្ថទ្ទស កុមារំ សោ   រមមានំ សកេ បុរេ
បរិកណ្ណំ អមច្ចេហិ   តិទសានំ វ វាសវំ ។
សោ តត្ថ គន្ត្វា តរមានោ   កត្តា វេស្សន្តរំ ព្រវិ
ទុក្ខន្តេ វេទយិស្សាមិ   មា មេ កុជ្ឈ រថេសភ ។
វន្ទិត្វា រោទមានោ សោ   កត្តា រាជានមព្រវិ
ភត្តា មេសិ មហារាជ   សព្វកាមរសាហរោ
ទុក្ខន្តេ វេទយិស្សាមិ   តត្ថ អស្សាសយន្តុ មំ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

សិវិយោ ចេវ តេ កុទ្ធា　　ចេតមា ច សមាគតា
ឧគ្គា ច រាជបុត្តា ច　　វេសិយានា ច ព្រាហ្មណា ។
ហត្ថារោហា អនីកដ្ឋា　　រថិកា បត្តិការកា
កេវលោ ចាបិ និគមោ　　សិវិយោ ចាបិ សមាគតា ។
អស្មា រត្យា វិវសនេ　　សុរិយស្សុគ្គមនំ បតិ
សមគ្គា សិវិយោ ហុត្វា　　រដ្ឋា បព្វាជយន្តិ តន្តិ ។

ភិក្ខវេ ម្នាលភិក្ខុទាំងឡាយអើយ កាលនោះព្រះបាទស្រីសញ្ជ័យ ព្រះអង្គមានព្រះបន្ទូលនឹងរាជអាមាត្យថា ម្នាលរាជអាមាត្យអើយ ចូរបាទៅប្រាប់បាវេស្សន្តរឥឡូវនេះឯង ថាបើអ្នកស្រីពិរាស្ត្រផងទាំងឡាយ គេខឹងនឹងបាវេស្សន្តរ ត្បិតតែអ្នកឲ្យទានដំរីរ័ត្នមង្គលប្រសើរទៅព្រាហ្មណ៍ ។ រីរាជអាមាត្យទទួលយកព្រះរាជបន្ទូលថ្លៃពិសេសហើយ ក្រាបថ្វាយបង្គំលាទៅកាន់សំណាក់ព្រះបរមពោធិសត្វក្រាបទូលព្រះបាទស្រីវេស្សន្តរថា បពិត្រក្សត្រដ៏ប្រសើរអើយ ក៏ឥឡូវនេះ អស់អ្នកស្រីពិរាស្ត្រផងទាំងឡាយ គេខឹងនឹងព្រះអង្គនេះណាស់ទោះព្រះរាជទេពីក្តី ព្រះរាជបុត្រក្តី នូវអស់ស្រីព្រះស្នំ ក្រមការភ្នាក់ងារ

Websites: WatKhemaraRatanaram.org or WatKhmers.org

ស្រុកស្រែក្រៅលំនៅជនបទ  កំណត់ស្រុកតូចធំ សមណព្រាហ្មណាចារ្យ  ភ្នាក់ងារ  នាយដំរី  នាយសេះ  នាយរទេះ  គេសឹងតែខឹងនឹងព្រះអង្គព្រមល្មមអស់ទៅហើយ ។ បពិត្រមហារាជអើយ នាព្រឹកស្អែកនេះឯង  លុះព្រះអាទិត្យរះឡើងហើយ  គេនឹងបំបរបង់ព្រះអង្គចេញទៅហោង ។

មហាសត្តោ អាហ ។ ព្រះមហាសត្វព្រះអង្គមានព្រះបន្ទូលទៅនឹងរាជអាមាត្យថា ៖

កិស្មឹ មេ សិវិយោ កុទ្ធា    យោ ន បស្សាមិ ទុក្កដំ
តំ មេ កត្តេ វិយាចិក្ខ    កស្មា បព្វាជយន្តិ មន្តិ ។

ថាម្នាលរាជអាមាត្យអើយ  ព្រោះរឿងអ្វីបានជាពួកអ្នកស្រីពិរាស្ត្រគេខឹងនឹងយើង  យើងមើលមិនឃើញអំពើអាក្រក់អ្វីឡើយ  ចូរអ្នកប្រាប់អំពើអាក្រក់នោះឲ្យយើងបានដឹងផង  ចុះហេតុអ្វីបានជាគេនាំគ្នាបំបរបង់យើងចេញ ។ រាជអាមាត្យនោះក្រាបបង្គំទូលស្នងថា ៖

ឧគ្គា ច រាជបុត្តា ច    វេសិយានា ច ព្រាហ្មណា
ហត្ថារោហា អនីកដ្ឋា    រថិកា បត្តិការកា

Websites: WatKhemaraRatanaram.org  or  WatKhmers.org

ឆាតកាសេ ខីយន្តិ     តស្មា បព្វាជយន្តិ តន្តិ ។

ពួកឧគ្គជន ពួករាជបុត្រ ពួកឈ្មួញ ពួកព្រាហ្មណ៍ ពួកពលដំរី ពួកពលសេះ ពួកពលរថ ពួកពលថ្មើរជើង នាំគ្នាត្អូញត្អែរដៀលខឹងនឹងព្រះអង្គ ព្រោះតែទ្រង់ព្រះរាជទានដំរីបច្ច័យនាគេន្ទ្រ ហេតុហ្នឹងហើយ បានជាគេនាំគ្នាបំបរបង់ព្រះអង្គចេញ ។

ព្រះមហាសត្វ ទ្រង់ស្ដាប់ហេតុភេទនោះហើយ មានព្រះទ័យសោមនស្សត្រាស់ថា ៖

ហទយំ ចក្ខុម្បហំ ទជ្ជំ     កឹ មេ ពាហិរកំ ធនំ
ហិរញ្ញំ វា សុវណ្ណំ វា     មុត្តា វេឡុរិយា មណិ
ទក្ខិណំ វាមហំ ពាហុំ     ទិស្វា យាចកមាគតេ
ទទេយ្យំ ន វិកម្បេយ្យំ     ទានេ មេ រមតី មនោ ។
កាមំ មំ សិវិយោ សព្វេ     បព្វាជេន្តុ ហនន្តុ វា
នេវ ទានា វិរមិស្សំ     កាមំ ឆិន្ទន្តុ សត្តជាតិ ។

ថាម្នាលរាជអាមាត្យអើយ កុំថាតែដំរីបច្ច័យនាគេន្ទ្រ ដែលអញឲ្យទៅជាទានព្រាហ្មណ៍នោះឡើយ អញគិតសព្វថ្ងៃនេះចង់តែនឹង

Websites: WatKhemaraRatanaram.org or WatKhmers.org

ឲ្យអជ្ឈត្តិកទាន គឺទានក្នុងខ្លួនអញឯងហ្ន៎ ឥឡូវនេះព្រាហ្មណ៍វាមកសូមដំរីបច្ច័យនាគេន្ទ្រ ហៅពាហិរកទាន គឺទានក្រៅអំពីរូបអញ ៗ នឹងស្ដាយថ្វីថៅអាមាត្យអើយ អស់អ្នកស្រីពិរាស្ត្រផងគេខឹងនឹងអញ ត្បិតអញឲ្យទាននោះ ទោះគេនឹងកាត់ខ្លួនអញជា ៧ កំណាត់ក្ដី ក៏អញមិនភ្លេចត្រង់ឲ្យទាននោះឡើយ ។

តំ សុត្វា កត្តា នេវ រញ្ញា ច ន ញាតកេហិ ទិន្នំ អត្តនោ មតិយា វ អបរំបិ សាសនំ កថេន្តោ អាហ ។

រាជអាមាត្យស្ដាប់ព្រះបន្ទូលព្រះបរមពោធិសត្វហើយ ក្រាបថ្វាយបង្គំប្រណម្យទូលពត៌មានដទៃទៀត ហេតុអាមាត្យនោះស្រឡាញ់ព្រះបរមពោធិសត្វនោះឯង ទើបក្រាបទូលជាបាទគាថាដូច្នេះថា ៖

ឯវន្តំ សិវិយោ អាហុ នេគមា ច សមាគតា
កោញ្ចិមាលាយ តីរេន គិរិមារញ្ជរំ បតិ
យេន បព្វជិតា យន្តិ តេន គច្ឆតុ សុព្វតោតិ ។

បពិត្រមហារាជអើយ រីអស់អ្នកស្រីពិរាស្ត្រផងទាំងឡាយគេជំនុំព្រមល្មមហើយ គេនឹងបណ្ដេញព្រះអង្គ ឲ្យទៅនៅភ្នំអរញ្ញ

Websites: WatKhemaraRatanaram.org or WatKhmers.org

បពិត  អាស្រ័យនឹងស្នឹងកោន្តិមារានទីហោង ។

តំ សុត្វា ពោធិសត្តោ ព្រះបរមពោធិសត្វ ទ្រង់ស្តាប់ពាក្យរាជអាមាត្យនោះហើយ  មានព្រះបន្ទូលថា  ប្រពៃហើយរាជអាមាត្យយើងនឹងដើរទៅតាមផ្លូវ ជាដំណើរនៃព្រះមហាក្សត្រដែលធ្វើខុសទាំងឡាយ  ប៉ុន្តែឥឡូវនេះ  ពួកអ្នកនគរគេបំបរបង់យើង មិនមែនដោយទោសដទៃឡើយ ព្រោះតែយើងឲ្យដំរីវ័ត្នទៅជាទានព្រាហ្មណ៍ បើដូច្នេះទុកបង្អង់ឲ្យយើងឲ្យសត្តសតកមហាទានបាន ១ ថ្ងៃសិន សូមឲ្យអ្នកនគរបង្អង់ទុកឱកាសឲ្យយើង ១ ថ្ងៃសិន ដល់ព្រឹកស្អែក យើងបានឲ្យទានរួចហើយ  សឹមយើងទៅក្នុងថ្ងៃខានស្អែក  ហើយទ្រង់សូត្រជាបាទគាថាដូច្នេះថា ៖

សោហំ តេន គមិស្សាមិ  យេន គច្ឆន្តិ ទុសកា
រត្តិន្ទិវំ មេ ខមថ  យាវ ទានំ ទទាមិហន្តិ ។

យើងនឹងទៅតាមផ្លូវរបស់ក្សត្រដែលធ្វើខុស សូមអ្នកទាំងឡាយ  អត់ទោសបង្អង់ឲ្យយើង ១ យប់ ១ ថ្ងៃសិន ទម្រាំយើងឲ្យទានស្រេច ។

Websites: WatKhemaraRatanaram.org or WatKhmers.org

តំ សុត្វា កត្តា រាជអាមាត្យស្តាប់ព្រះបន្ទូលថ្លៃនៃព្រះពោធិសត្វហើយ ក៏ទទួលយកព្រះបន្ទូលពិសេស ទៅក្រាបបង្គំទូលព្រះបាទស្រីសញ្ជ័យ មួយអន្លើនឹងអស់អ្នកស្រីពិរាស្ត្រផងទាំងពួង ។

កាលនោះ ព្រះបរមពោធិសត្វមហាបុរសរ័ត្នវិសេស ព្រះអង្គឲ្យដំណើររាជអាមាត្យនោះទៅហើយ ឯក្រោយនោះឯង ព្រះអង្គមានព្រះបន្ទូលបង្គាប់ប្រើសេនាបតីមួយដ៏ជាធំ ថាហៃសេនាបតីដ៏ជាធំអើយ ចូរព្រះស្តែងទៅប្រដាប់នូវដំរីនោះបាន ៧០០, សេះ ៧០០, រទេះ ៧០០, ស្រីកញ្ញា ៧០០, មេគោឆ្នាត់ ៧០០, គោឧសភរាជ ៧០០, ខ្ញុំស្រី ៧០០, ខ្ញុំប្រុស ៧០០ មួយអន្លើនូវបាយទឹក សំពត់អាវសារស្បៃមាសប្រាក់កែវកង សព្វពិធរ័ត្នផងទាំងពួង ដោយហោចទៅ សូម្បីសុរារបស់មិនគួរឲ្យជាទាន ចូរព្រះស្តែងប្រដាប់មហាទាន ឲ្យមានសព្វគ្រប់ ។ នាព្រឹកស្អែកនេះ អញនឹងចេញចាយសត្តសតកមហាទានស្រេចហើយ លុះព្រឹកខានស្អែកឡើង អញនឹងចេញអំពីស្រុកនេះទៅហើយ ។ ម្ល៉ោះហើយព្រះអង្គឲ្យដំណើរសេនាបតីនោះទៅកាន់លំនៅអាត្មាវិញហោង ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ឯកតោរ មទ្ទិយា វេសន្តរំ តត្ថ សិរិសយនបិដ្ឋេ និសីទិត្វា តាយ សទ្ធឹ កថំ បវត្តេសិ ។ ឯក្រោយនោះឯង ព្រះបរមពោធិសត្វព្រះអង្គលីលា ទៅកាន់ឋានលំនៅនាងមទ្រីតែមួយព្រះអង្គទ្រង់គង់លើខ្នងកម្រាលមានសិរីសួស្តីហើយ ហើយសំណេះសំណាលជាមួយនឹងព្រះនាងមទ្រីនាកាលណោះហោង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ ។ វីអាថ៌ធម៌ឯណាពុំប្រាកដ បទព្រះបាលីឯណាពុំទាន់ថៃងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គបន្ទូលនឹងភិក្ខុផងទាំងឡាយ សូត្រជាបាទគាថាដូច្នេះថា ៖

អាមន្តយិត្ថ រាជា នំ មទ្ទឹ សព្វង្គសោភិនឹ
យំ តេ កញ្ចិ មយា ទិន្នំ ធនំ ធញ្ញញ្ច វិជ្ជតិ
ហិរញ្ញំ វា សុវណ្ណំ វា មុត្តា វេឡុរិយា ពហូ
សព្វន្តំ និទហេយ្យាសិ យញ្ច តេ បេត្តិកំ ធនន្តិ ។

ភិក្ខវេ ម្នាលភិក្ខុផងទាំងឡាយអើយ ឰដ៏កាលនោះ ព្រះបាទស្រីវេស្សន្តរ ស្តេចមានព្រះបន្ទូលទៅនឹងព្រះនាងមទ្រីទេវីថា ម្នាល

មទ្រីនាងអើយ វិទ្រព្យឯណានីមួយទោះមាសក្តី ប្រាក់ក្តី កែវមុក្តាក្តី កែវពៃទូរ្យជាច្រើនក្តី ទោះបីទ្រព្យផងណាដែលសម្តេចព្រះវររាជបិតាប្រទានឲ្យនាងក្តី ក៏ចូរនាងកប់ទុកឲ្យល្អប្រពៃសព្វគ្រប់ហោង ។

តមព្រវិ រាជបុត្តី មទ្ទី សព្វង្គសោភណា
កាហំ ទេវ និទហាមិ តំ មេ អក្ខាហិ បុច្ឆិតោតិ

សម្តេចព្រះភគវតី ព្រះនាងមទ្រីដ៏ទ្រង់នូវលក្ខណា ដ៏ប្រសើរ ទ្រង់ស្តាប់ហើយ ព្រះនាងក្រាបទូលព្រះរាជស្វាមីថា បពិត្រក្សត្រថ្លៃប្រសើរអើយ អញខ្ញុំសូមទូលសួរ សូមទ្រង់ថ្លែងប្រាប់ វិទ្រព្យទាំងអម្បាលណោះ តើអញខ្ញុំនឹងគ្រប់គ្រងកប់ទុកក្នុងទីណា ព្រះបាទស្រីវេស្សន្តរទ្រង់ស្តាប់ហើយ ទ្រង់មានព្រះបន្ទូលថា ៖

សីលវន្តេសុ ទជ្ជេសិ ទានំ មទ្ទិ យថារហំ
ន ហិ ទានា បរំ អត្ថិ បតិដ្ឋា សព្វបាណីនន្តិ ។

ថាមទ្រីទេវីនាងអើយ ចូរនាងឲ្យទានដល់សមណព្រាហ្មណាចារ្យ ស្មូមយាចក អ្នកកំសត់ទុគ៌តផងទាំងឡាយចុះ ព្រោះទានជាទីពឹងពំនាក់របស់សត្វផងទាំងឡាយ មិនមានទីពឹងដទៃក្រៅពីទាន

Websites: WatKhemaraRatanaram.org or WatKhmers.org

ឡើយ ។

ព្រះនាងមទ្រីទ្រង់ស្ដាប់ហើយ ថ្វាយបង្គំប្រណម្យទូលថា បពិត្រព្រះបាទស្រីវេស្សន្តរដ៏ជាស្វាមីខ្ញុំអើយ ព្រះអង្គមានព្រះបន្ទូលនោះ គាប់ប្រពៃពិតពេកណាស់ហោង ។ ទើបព្រះមហាសត្វប្រទានឱវាទដំបូន្មានតទៅទៀតថា ៖

បុត្តេសុ មទ្ទិ ទយេសិ សស្សុយា សស្សុរម្ហិ ច
យោ ច តំ ភត្តា មញ្ញេយ្យ សក្កច្ចំ ឧបដ្ឋហេ ។

ថាម្នាលនាងមទ្រីអើយ អំណើះអស់នឹងអញទៅហើយ ក៏ចូរនាងរក្សាកូនទាំងពីរឯក្រោយ ហើយឲ្យនាងបម្រើអ្នកទាំងពីរដ៏ជាមេក្មេក បាក្មេក និងអ្នកដែលមកជាភស្តារបស់នាង ដោយនូវវត្តប្រតិបត្តិទាំងពួងហោង ។

នោ ចេ តំ ភត្តា មញ្ញេយ្យ មយា វិប្បវសេន តេ
អញ្ញំ ភត្តារំ បរិយេស មា កិលិត្ថ មយា វិនាតិ ។

ថាម្នាលនាងមទ្រីអើយ កាលណាបើអំណើះអំពីអញទៅហើយ ទោះយោបីមានអ្នកឯណាមួយ គេប្រាថ្នាចង់បាននាងជាប្រពន្ធ

Websites: WatKhemaraRatanaram.org or WatKhmers.org

ក៏ចូរនាងទៅនៅបម្រើគេជាភស្តាថ្មីចុះ  កុំបីមានសេចក្ដីព្រួយលំបាកព្រោះការព្រាត់ប្រាសចាកអញនេះឡើយ ។

ព្រះនាងមទ្រីទ្រង់ស្ដាប់ហើយ ទ្រង់ព្រះតម្រិះថា ហេតុអ្វីហ្ន៎ក៏ព្រះរាជស្វាមីត្រាស់ព្រះវាចាដូច្នេះ  ទើបព្រះនាងក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេពក្សត្រថ្លៃប្រសើរអើយ  ហេតុអ្វីក៏ព្រះអង្គមានព្រះបន្ទូលនូវពាក្យមិនគួរគប្បីដូច្នេះ ។ ទើបព្រះមហាសត្វមានព្រះបន្ទូលតបថា  មទ្រីនាងអើយ ឥឡូវនេះ អ្នកស្រីពីរាស្ត្រផងទាំងឡាយគេខឹងនឹងអញ ត្បិតតែអញឲ្យទានដំរីរ័ត្នមង្គលប្រសើរនោះ ឥឡូវគេបណ្ដេញអញចេញចាកស្រុកនេះ  អញនៅតែថ្ងៃនេះឯង  នាថ្ងៃព្រឹកស្អែកនោះអញនឹងឲ្យសត្តសតកមហាទាន  លុះថ្ងៃគម្រប់បី  អញនឹងចេញចាកស្រុកនេះទៅហោង ហើយព្រះអង្គមានព្រះបន្ទូលជាបាទគាថាដូច្នេះថា

អហំ ហិ វនំ គច្ឆាមិ  យោវំ វាឡមិគាយុតំ

សំសយោ ជីវិតំ មយ្ហំ  ឯកកស្ស ព្រហាវនេតិ ។

ម្នាលនាងមទ្រីហើយ  អញនឹងចេញទៅនៅ  នាព្រៃហេមពាន្តនាយ ច្រឡំនីទៅនូវសត្វម្រឹគបក្សីផងទាំងឡាយច្រើន  ជាដើមគឺ

Websites: WatKhemaraRatanaram.org or WatKhmers.org

រាជសីហ៍ ដំរីព្រៃ រមាំង រមាស ដេរដាសនីទៅនូវខ្លាធំ ខ្លាដំបង ទន្សោង ខ្លែង គោព្រៃផងច្រើន ។ មទ្រីនាងអើយ ជីវិតអញមួយនេះ អញនឹងសង្ស័យថារស់នៅនោះពុំមានឡើយ ។ តេន វុត្តំ ហេតុនោះ ហោង ព្រះអង្គបានត្រាស់ហើយ មានព្រះបន្ទូលនឹងភិក្ខុផងទាំងឡាយ ស្ងូត្រជាបាទគាថាដូច្នេះថា ៖

តមព្រវិ រាជបុត្តី មទ្ទី សព្វង្គសោភណា
អភុម្ម កថំ នុ ភណសិ បាបកំ វត ភាសសិ
នេស ធម្មោ មហារាជ យំ ត្វំ គច្ឆេយ្យ ឯកកោ
អហំបិ តេន គច្ឆាមិ យេន គច្ឆសិ ខត្តិយ ។
មរណំ វា តយា សទ្ធឹ ជីវិតំ វា តយា វិនា
តទេវ មរណំ សេយ្យោ យញ្ចេ ជីវេ តយា វិនា ។
អគ្គឹ ឧជ្ជាលយិត្វាន ឯកជាលសមាហិតំ ។
តត្ថេវ មរណំ សេយ្យោ យញ្ចេ ជីវេ តយា វិនា ។
យថា អារញ្ញកំ នាគំ ទន្តឹ អន្វេតិ ហត្ថិនី

Websites: WatKhemaraRatanaram.org or WatKhmers.org

ជេស្សន្តំ គិរីទុគ្គេសុ សមេសុ វិសមេសុ ច
ឯវន្តំ អនុគច្ឆាមិ បុត្តេ អាទាយ បច្ឆតោ
សុភគា តេ ភវិស្សាមិ ន តេ ហេស្សាមិ ទុព្ភរាតិ ។

ភោ សារីបុត្ត ហៃសារីបុត្រអើយ រីសម្តេចព្រះភគវតីនាងមទ្រី ដ៏ប្រកបនូវបញ្ចពិធកល្យាណី ជាព្រះរាជបុត្រី ស្ត្រីត្រកូលសំបូរជាតិព្រះបាទមទ្ទរាស្ត្រនោះ ព្រះនាងឮព្រះបន្ទូលព្រះបរមពោធិសត្វហើយ ព្រះនាងទ្រង់ព្រះកន្សែងសោយសោកថា បពិត្រព្រះសម្មតិទេព មហារាជក្សត្រថ្លៃប្រសើរអើយ រីព្រះបន្ទូលព្រះអង្គនោះ យល់អាក្រក់ក្រៃពេក មិនសុភាពដោយនូវគន្លងធម៌ឡើយ ។ អម្ចាស់វិសេសខ្ញុំអើយ ព្រះអង្គនឹងស្តេចដើរទៅត្រង់ឋានឯណាមិញ ក៏អញខ្ញុំនឹងពមេក្រស្នា បណ្តើរបាជាលីទៅដោយនូវផ្លូវនោះហោង ។ បពិត្រក្សត្រថ្លៃប្រសើរអើយ ថាបើអញខ្ញុំប្រាសនិរាសពីព្រះអង្គហើយ អញខ្ញុំនឹងយកឧសមកគរប្រមាណកំពស់ភ្នំ ហើយអញខ្ញុំនឹងយកភ្លើងមកដុរឱ្យឆេះឡើង ដ៏មានអណ្តាតភ្លើងនោះស្មើគ្នាល្អហើយ ខ្ញុំនឹងលោតចុះក្នុងភ្លើងនោះឲ្យស្លាប់ទៅវិញ ក៏ប្រសើរក្រៃពេកហោង ។ បពិត្រព្រះ

Websites: WatKhemaraRatanaram.org or WatKhmers.org

បាទស្រីវេស្សន្តរអម្ចាស់វិសេសខ្ញុំអើយ ព្រះអង្គដូចជាបាដំរីដើរត្រាច់ក្នុងព្រៃសព្វជ្រោះជ្រលងដងភ្នំទាំងពួង ឯខ្ញុំម្ចាស់សោតដូចមេដំរីបណ្តើរកូនទាំងពីរ តាមដោយគន្លងព្រៃភ្នំទាំងពួងនោះដែរ ។

ឯវំ វត្វា បុន សោ ធិជ្ជបុត្តំ វិយ ហិមវន្តប្បទេសំ វណ្ណេន្តី អាហ ។ វីសម្តេចព្រះភគវតីនាងមទ្រី ព្រះនាងទ្រង់ព្រះកន្សែងម្ល៉ោះហើយក្តី ព្រះនាងសរសើរព្រៃហេមពាន្តហានប្រទេសមានប្រការនោះផ្សេងៗ ទូលព្រះពោធិសត្វ ហាក់ដូចជាព្រះនាងបានយល់ពីមុនមកហើយ ទ្រង់សូត្រជាបាទគាថាទាំងឡាយដូច្នេះ ៖

ឥមេ កុមារេ បស្សន្តោ មញ្ជុកេ បិយភាណិនេ
អាសិនេ វនគុម្ពស្មឹ ន រជ្ជស្ស សរិស្សសិ ។
ឥមេ កុមារេ បស្សន្តោ មញ្ជុកេ បិយភាណិនេ
កីឡន្តេ វនគុម្ពស្មឹ ន រជ្ជស្ស សរិស្សសិ
ឥមេ កុមារេ បស្សន្តោ មញ្ជុកេ បិយភាណិនេ
អស្សមេ រម្មណីយម្ហិ ន រជ្ជស្ស សរិស្សសិ ។
ឥមេ កុមារេ បស្សន្តោ មញ្ជុកេ បិយភាណិនេ

Websites: WatKhemaraRatanaram.org or WatKhmers.org

កីឡន្តេ អស្សមេ រម្មេ  ន រជ្ជស្ស សរិស្សសិ ។
ឥមេ កុមារេ បស្សន្តោ  មាលធារី អលង្កតេ
អស្សមេ រមណីយម្ហិ  ន រជ្ជស្ស សរិស្សសិ ។
ឥមេ កុមារេ បស្សន្តោ  មាលធារី អលង្កតេ
កីឡន្តេ អស្សមេ រម្មេ  ន រជ្ជស្ស សរិស្សសិ ។
យទា ទក្ខសិ នច្ចន្តេ  កុមារេ មាលធារិនេ
អស្សមេ រមណីយម្ហិ  ន រជ្ជស្ស សរិស្សសិ ។
យទា ទក្ខសិ នច្ចន្តេ  កុមារេ មាលធារិនេ
កីឡន្តេ អស្សមេ រម្មេ  ន រជ្ជស្ស សរិស្សសិ ។
យទា ទក្ខសិ មាតង្គំ  កុញ្ជរំ សដ្ឋិហាយនំ
ឯកំ អរញ្ញេ វិចរន្តំ  ន រជ្ជស្ស សរិស្សសិ ។
យទា ទក្ខសិ មាតង្គំ  កុញ្ជរំ សដ្ឋិហាយានំ
សាយំ ចាតោ វិចរន្តំ  ន រជ្ជស្ស សរិស្សសិ ។
យទា ករេណុសង្ឃស្ស  យូថស្ស បុរតោ វជំ

Websites: WatKhemaraRatanaram.org or WatKhmers.org

កោញ្ចំ កាហតិ មាតង្គោ កុញ្ជរោ សដ្ឋិហាយនោ
តស្ស តំ នទតោ សុត្វា ន រជ្ជស្ស សរិស្សសិ ។
ឧភតោ វនវិកាសេ យទា ទក្ខសិ កាមទំ
វនេ វាឡមិគាកិណ្ណេ ន រជ្ជស្ស សរិស្សសិ ។
មិគំ ទិស្វាន សាយណ្ហំ បញ្ចមាលិនិមាគតំ
កឹបុរិសេ ច នច្ចន្តេ ន រជ្ជស្ស សរិស្សសិ ។
យទា សុស្សសិ និគ្ឃោសំ សន្ទមានាយ សិន្ធុយា
គីតំ កឹបុរិសានញ្ច ន រជ្ជស្ស សរិស្សសិ ។
យទា សុស្សសិ និគ្ឃោសំ គិរិគព្ភរចារិនោ
វសមានស្សុលូកស្ស ន រជ្ជស្ស សរិស្សសិ ។
យទា សីហស្ស ព្យគ្ឃស្ស ខគ្គស្ស គវយស្ស ច
វនេ សុស្សសិ វាឡានំ ន រជ្ជស្ស សរិស្សសិ ។
យទា មោរីហិ បរិកិណ្ណំ វរហិនំ មត្ថកាសិនំ
មោរំ ទក្ខសិ នច្ចន្តំ ន រជ្ជស្ស សរិស្សសិ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

យថា មោរីហិ បរិកិណ្ណំ    អណ្ឌជំ ចិត្របេក្ខណំ
មោរំ ទក្ខសិ នច្ចន្តំ    ន រជ្ជស្ស សរិស្សសិ ។
យថា មោរីហិ បរិកិណ្ណំ    នីលគីវំ សិខណ្ឌិនំ
មោរំ ទក្ខសិ នច្ចន្តំ    ន រជ្ជស្ស សរិស្សសិ ។
យថា ទក្ខសិ ហេមន្តេ    បុប្ផិតេ ធរណីរុហោ
សុរភិសម្បវាយន្តេ    ន រជ្ជស្ស សរិស្សសិ ។
យថា ហេមន្តិកេ មាសេ    ហរិតំ ទក្ខសិ មេទនិំ
ឥន្ទគោបកសញ្ឆន្នំ    ន រជ្ជស្ស សរិស្សសិ ។
យថា ទក្ខសិ ហេមន្តេ    បុប្ផិតេ ធរណីរុហោ
កុដជំ ពិម្ពជាលញ្ច    បុប្ផិតំ លោទបទ្មកំ
សុរភិសម្បវាយន្តេ    ន រជ្ជស្ស សរិស្សសិ ។
យថា ហេមន្តិកេ មាសេ    វនំ ទក្ខសិ បុប្ផិតំ
ឱបុប្ផានិ បទុមានិ    ន រជ្ជស្ស សរិស្សសីតិ ។

បពិត្រមហារាជក្សត្រថ្លៃប្រសើរអើយ    រីព្រៃហេមពាន្តនោះ

Websites: WatKhemaraRatanaram.org or WatKhmers.org

សប្បាយក្តាត់ហោង កាលបើយើងទៅដល់ហើយ រីក្មេងទាំងពីរនេះ នាកាលថ្ងៃរសៀល វានឹងច្រៀងរាំលេង ដោយនៅនាដង្គំព្រៃនោះ មានសម្លងមូលសសូល ក្រាំងក្រអៅជ្រៅជ្រះ សមន្ទរស័ព្ទដ៏ពីរោះ សមព្រះអង្គនឹងសប្បាយ ក្នុងព្រះហឫទ័យម្រ៉ាងឡើយ ព្រះអង្គនឹងនឹករលឹកមកកាន់រាជ្យសម្បត្តិឯអាយ ។

បពិត្រមហារាជក្សត្រថ្លៃប្រសើរអើយ រីបាដំរីព្រៃដ៏ល្អដ៏មានចាមរ នោះល្ហាយល្អងរាំងគន្លងបោសព្រះធរណី ដ៏មានសម្បុរនោះខៀវ បីដូចផ្ទៃមហាមេឃ ដ៏មានភ្លុកធំល្អ ទោះល្វាចក្តី ព្រឹកក្តី វាដើរទៅមុន ញីខ្លោងទាំងឡាយ ហើយវាស្រែកស្នៀរសម្លេងដូចក្រៀលសមនឹងសប្បាយព្រះរាជហឫទ័យ ម្រ៉ាងឡើយ ក៏នឹងនឹករលឹកមកកាន់រាជ្យសម្បត្តិឯអាយ ។ រីពពួកកិន្នរផងទាំងឡាយ បីដូចនូវមនុស្សសឹងដ៏មានរូបឆោមនោះល្អស្រឡះស្រលូតល្អួតល្ពៅ ស្រដៅស្រដើខ្លះរាំ ខ្លះច្រៀង ខ្លះបណ្តើរគ្នាលេងដោយសងខាងមុចលិន្ទនទី ដ៏មីរដេរដាសបីដូចជារបាំរាំរំពេន មានឮដ៏ជេតុត្តរនគរនោះឯងហោង ថាបើព្រះអង្គយល់ហើយ ម្រ៉ាងឡើយ នឹងនឹករលឹកមកកាន់រាជ្យសម្បត្តិឯអាយ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

បពិត្រព្រះមហាក្សត្រថ្លៃប្រសើរអើយ រីភ្នំគិរីវង្កតបពិតនោះ មានប្រាសាទគុហាសឹងមាស ដាសសឹងប្រាក់ផងច្រើន ច្រទ្បំនីទៅនូវក្ងោក ប៉ោលតោក តាវ៉ៅ រីទឹកនោះសោតសឹងដ៏ហូរមក ដ៏មានសូរស័ព្ទនោះ ពីរោះស្មើបីដូចអ្នកសេពសមផ្លុំប្រគំនូវតូរ្យតន្ត្រី ឮដ៏ជេតុត្តរនគរនោះហោង ថាបើព្រះអង្គយល់ហើយ ម្រ៉ាងឡើយនឹងនឹករលឹកមកកាន់ រាជសម្បត្តិឯអាយ ។

បពិត្រមហារាជក្សត្រថ្លៃដ៏ប្រសើរអើយ រីម្រឹគផងទាំងឡាយច្រើនជាដើម គឺរាជសីហ៍ ដំរីព្រៃ រមាំង រមាស ខ្លាធំ ខ្លាដំបង គោព្រៃផងផ្សេងៗ សឹងដ៏អួតជល់គ្នាទៅវិញទៅមក បោលដេញគ្នាលេងថាបើព្រះអង្គបានយល់ហើយ ម្រ៉ាងឡើយនឹងនឹករលឹកមកកាន់រាជ្យសម្បត្តិឯអាយ ។

មួយនីសោត ទោះល្ងាចក្តី ព្រឹកក្តី អម្ចាស់នឹងលីលាទៅក្រសាលនៅក្រោមម្លប់ជ្រៃក្តី ម្លប់ព្រីងក្តី អម្ចាស់ទតរមិលមើលទៅពពួកក្ងោកញីឈ្មោលទាំងឡាយ សឹងដ៏ច្រើនក្តាត់ហោង សឹងដ៏មានរបៀបស្លាប នូវកន្ទុយនោះល្អ មានផ្ទត់កនោះខៀវ មានសិរនោះវែង

Websites: WatKhemaraRatanaram.org or WatKhmers.org

មានកំណើតនោះពីរដង គឺថាពងហើយញាស់ចេញជាកូន រីក្ងោក ឈ្មោលសោត តែងនឹងពង់កំទារក្ងោកញី ៗ ជាបរិពារតែងនឹងរាំពេន ពង់លេង ថាបើអម្ចាស់បានយល់ហើយ សមអម្ចាស់សប្បាយក្នុង ព្រះរាជហឫទ័យ ម្រាំងឡើយ នឹងទ្រង់នឹករលឹកមកកាន់រាជ្យសម្បត្តិ ឯអាយ ។

បពិត្រមហារាជអើយ រីឈើផងទាំងឡាយ ដុះព្ធដ៏សងខាង ផ្លូវ ថ្មល់នោះសោត ដ៏មានខ្លែងគង់ បំពង់កាំ ផ្គាំស ពុំសែនទេស កាកេស កណ្ណិការ ក្តាំងងា ខ្ទឹងក្ទម្ព សមន្ទូវសុរភី ចម្ប៉ាចំប៉ី សឹងដ៏មាន ក្លិននោះ ពិដោរ កាលណាបើខ្យល់បក់ហើយផ្ងុំហ្បូងត្រឡប់ក្រៃពេក ។ មួយនីសោត បើអម្ចាស់នឹងចង្ក្រមព្ធដ៏ថ្មល់មុច្ចលិន្ទស្រះ ក៏ព្រះអង្គនឹង ទត រមិលមើលទៅព្ធដ៏ផ្ទៃស្រះនោះ ដ៏មានផ្កាឈ្យូកច្រាល ឈ្យូកស ដ៏រីករន្ទាល នីទៅន្ទូវស្ប៉ង្កជ ឧត្បុលចង្កុលណី ព្រលឹត លំចង់ សឹងដ៏រីកស្គុសស្គាយពណ្ណរាយសោភា សឹងដ៏មានទឹកនោះថ្លាត្រជាក់ ជាពំនាក់នៃត្រីផងដ៏មានច្រាំងនោះទាប កំពង់នោះរាបបីដូចន្ទូវស្រះ មានព្ធដ៏ជេតុត្តរនគរនេះឯងហោង ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**ឯវំ មទ្ទី ហេមវន្តភាសិដី វិយ ឯត្តកាហិ គាថាហិ ហិមវន្តំ វណ្ណេសិ** ។ រីសម្តេចព្រះភគវតីព្រះនាងមទ្រី ដ៏ប្រកបនូវបញ្ចពិធកល្យាណីដ៏ជាស្រីរ័ត្នឧត្តម សមនូវទម្រង់ កំពស់ប្រពៃ បានអភិសេកជាឯកអគ្គមហេសី ព្រះនាងសរសើរព្រៃហេមពាន្ត ហាក់ដូចព្រះនាងធ្លាប់គង់នៅព្រៃហេមពាន្ត មកជាយូរអង្វែងហើយ ទើបព្រះនាងសម្តែងថ្លែងដំណើរនិយាយស្រាយប្រាយប្រាប់ព្រះមហាក្សត្រ សូត្រជាបាទគាថានូវប្រការអម្បាលណោះឯងហោង ។

**ហិមវន្តំ និដ្ឋិតំ** បពិត្រអើយ អាត្មាភាពសំដែងថ្លែងព្រះធម៌វិសេសទេសនា ព្រះមហាជាតក៏កណ្ឌហេមពាន្តនេះមិញ ដ៏ប្រដាប់ប្រដានីទៅនូវគាថា ១៣៤ គាថា ក៏ចប់បរិបូណ៌សមគួរ ដោយនូវវេលានេះឯងហោង ៕ល៚

(ចប់កណ្ឌហេមពាន្តទី ២ តែប៉ុណ្ណោះ)

Websites: WatKhemaraRatanaram.org or WatKhmers.org

វាយខំព្យូទ័រសាឡើងវិញ

ដោយ

**លោកគ្រូអាចារ្យ ឈឹម សំបូរ**

និង

ត្រួតពិនិត្យកែសម្រួលអក្ខរាវិរុទ្ធ

ដោយ

លោកគ្រូ **ធម្មនាថ ផនប្រសិទ្ធិ៍**

ដើម្បីផ្សព្វផ្សាយ ជូនជាធម្មទាន តាមវិបសាយ

សព្វទានំ ធម្មទានំ ជិនាតិ ធម្មទានឈ្នះអស់ទានទាំងពួង

Websites: WatKhemaraRatanaram.org or WatKhmers.org